ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# ផែនការអភិវឌ្ឍន៍ស្ថាប័ន
# វិទ្យាស្ថានជាតិស្ថិតិ
# ឆ្នាំ២០២៦-២០២៨

ឆ្នាំ ២០២៦

# ផែនការអភិវឌ្ឍន៍ស្ថាប័ន
# វិទ្យាស្ថានជាតិស្ថិតិ
# ឆ្នាំ២០២៦-២០២៨


**រៀបចំដោយ៖**

ក្រុមការងារចំពោះកិច្ចអន្តរក្រសួង-ស្ថាប័ន សម្រាប់ការសិក្សា
និងរៀបចំសេចក្តីព្រាងផែនការពង្រឹងសមត្ថភាពវិទ្យាស្ថានជាតិស្ថិតិ



**គាំទ្របច្ចេកទេសដោយ៖**

ប្រទេសអូស្ត្រាលី តាមរយៈកម្មវិធីភាពជាដៃគូកម្ពុជា-អូស្ត្រាលី
សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ ( CAPRED )

# អារម្ភកថា

អស់រយៈពេលជាងពីរទសវត្សរ៍នៃសុខសន្តិភាព និងស្ថិរភាពនយោបាយ ដែលកើតចេញពីការអនុវត្តគោលនយោបាយឈ្នះ-ឈ្នះ កម្ពុជាបានយកចិត្តទុកដាក់ លើកិច្ចខិតខំប្រឹងប្រែងស្តារ និងកសាងមូលដ្ឋានសង្គម-សេដ្ឋកិច្ច ដោយបានអភិវឌ្ឍយ៉ាងឆាប់រហ័ស ជាមួយនឹងសមិទ្ធផលច្រើនឥតគណនាលើគ្រប់វិស័យ គួរជាទីមោទនៈ។ ឈរលើមូលដ្ឋាននេះ រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ក្នុងគោលដៅកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យ កម្ពុជាឆ្នាំ២០៥០។

ក្នុងដំណាក់កាលអន្តរកាលដ៏សំខាន់នេះ រាជរដ្ឋាភិបាលមើលឃើញពីភាពចាំបាច់ក្នុងការពង្រឹងការអនុវត្តមុខងាររបស់ស្ថាប័នរដ្ឋនីមួយៗ ដើម្បីចូលរួមកសាងមូលដ្ឋានគ្រឹះផ្នែកសង្គម-សេដ្ឋកិច្ច ដែលគាំទ្រដល់ការសម្រេចបាននូវចក្ខុវិស័យរយៈពេលវែងនេះដោយជោគជ័យ។ ទន្ទឹមនេះ ក្នុងបរិការណ៍ ដែលស្ថានភាពសេដ្ឋកិច្ចសកល ក៏ដូចជាសេដ្ឋកិច្ចកម្ពុជាផ្ទាល់ បន្តហ៊ុមព័ទ្ធដោយភាពមិនប្រាកដប្រជា និងហានិភ័យកាន់តែខ្ពស់ រាជរដ្ឋាភិបាលដាក់ចេញនូវទិសដៅអាទិភាព ក្នុងការពង្រឹងការកសាងប្រព័ន្ធស្ថិតិជាតិឱ្យកាន់តែប្រសើរឡើង ដើម្បីជាមូលដ្ឋានក្នុងការសម្រេចចិត្តផ្នែកគោលនយោបាយ ការដាក់ចេញការអន្តរាគមន៍ចំពោះមុខ និងការតម្រង់ទិសការអភិវឌ្ឍរយៈពេលវែង ដោយឈរលើមូលដ្ឋានទិន្នន័យស្ថិតិ ដែលមានគុណភាពខ្ពស់។ ប្រព័ន្ធស្ថិតិជាតិទំនើប ត្រូវធានាផ្តល់ទិន្នន័យស្ថិតិប្រកបដោយគុណភាព ភាពសម្បូរបែប ភាពជឿទុកចិត្តបាន ទាន់ពេលវេលា ដល់រាជរដ្ឋាភិបាលក្នុងការស្វែងយល់កាន់តែប្រសើរ សម្រាប់កិច្ចអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងប្រជាសាស្ត្រ ការរៀបចំគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ការតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និងការរៀបចំកម្មវិធីកែទម្រង់ និងវិធានការអន្តរាគមន៍ សំដៅឆ្លើយតបនឹងនិន្នាការនានាដែលបាន និងកំពុងលេចចេញជារូបរាងថ្មីៗ ដែលមានកម្មវិបាកទាំងវិជ្ជមាន និងអវិជ្ជមានមកលើសេដ្ឋកិច្ចកម្ពុជា។

ស្របតាមការចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់ និងប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលដៅក្នុងការកែទម្រង់ និងពង្រឹងសមត្ថភាពវិទ្យាស្ថានជាតិស្ថិតិ ដើម្បីប្រែក្លាយស្ថាប័ននេះ ទៅជាស្ថាប័នដើរតួនាទីស្នូលរបស់រាជរដ្ឋាភិបាល លើការប្រមូល និងវិភាគទិន្នន័យសម្រាប់ប្រទេសទាំងមូល។ ក្នុងទិសដៅនេះ រាជរដ្ឋាភិបាលបានប្រែក្លាយវិទ្យាស្ថានជាតិស្ថិតិ ទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ក្នុងឆ្នាំ២០២៥ ដោយបានកែសម្រួលរចនាសម្ព័ន្ធស្ថាប័ន ដើម្បីពង្រឹងប្រសិទ្ធភាពមុខងារ និងបង្កើនស័ក្តិសិទ្ធភាពប្រតិបត្តិការ ព្រមទាំងបង្កើតឡើងនូវក្រុមប្រឹក្សាភិបាលមួយ ដែលជាយន្តការអភិបាលកិច្ចកម្រិតយុទ្ធសាស្ត្ររបស់វិទ្យាស្ថាន។ ការបោះជំហានដើម្បីជំរុញ និងតម្រង់ទិសការកែទម្រង់វិទ្យាស្ថានជាតិស្ថិតិ មានចក្ខុវិស័យក្នុងការអភិវឌ្ឍស្ថាប័ននេះ ឱ្យមានសមត្ថភាពពេញលេញ

ក្នុងការផលិត និងចែករំលែកទិន្នន័យស្ថិតិ ប្រកបដោយគុណភាព ភាពសម្បូរបែប ភាពជឿទុកចិត្ត ទាន់ពេល និងគណនេយ្យភាពវិជ្ជាជីវៈ សំដៅលើកកម្ពស់ប្រព័ន្ធស្ថិតិជាតិស្របតាមស្តង់ដា ក្រឹត្យក្រម និងឧត្តមានុវត្តន៍អន្តរជាតិ។

ការដាក់ចេញនូវ **"ផែនការអភិវឌ្ឍន៍ស្ថាប័ន វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០២៦-២០២៨"** នឹងក្លាយជារបៀបវារៈស្នូលនៃការកែទម្រង់ និងពង្រឹងសមត្ថភាពវិទ្យាស្ថានជាតិស្ថិតិ ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការប្រមូល ការចងក្រង ការកែច្នៃ ការវិភាគ និងការផ្សព្វផ្សាយទិន្នន័យស្ថិតិ ព្រមទាំងការសម្របសម្រួលប្រព័ន្ធស្ថិតិជាតិ។ ការកែទម្រង់ និងពង្រឹងសមត្ថភាពវិទ្យាស្ថានជាតិស្ថិតិ អាចចាត់ទុកបានជាគំរូមួយក្នុងការកែទម្រង់ស្ថាប័ន ប្រកបដោយភាពប្រាកដនិយម ឱ្យក្លាយជាស្ថាប័នដែលមានសមត្ថភាពខ្ពស់ ស្វ័យភាព គណនេយ្យភាព និងចីរភាព ព្រមទាំងទទួលបានការជឿទុកចិត្តខ្ពស់ពីសាធារណជន ស្ថាប័នរដ្ឋ វិស័យឯកជន សង្គមស៊ីវិល និងគ្រប់ដៃគូពាក់ព័ន្ធ។

ឆ្លៀតក្នុងឱកាសនេះ ក្នុងនាមក្រុមប្រឹក្សាភិបាល ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកទាំងអស់នៃវិទ្យាស្ថានជាតិស្ថិតិ ខ្ញុំសូមថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ ដល់**ក្រុមការងារចំពោះកិច្ចអន្តរក្រសួង-ស្ថាប័នសម្រាប់ការសិក្សា និងរៀបចំសេចក្តីព្រាងផែនការពង្រឹងសមត្ថភាពវិទ្យាស្ថានជាតិស្ថិតិ** និងការគាំទ្រផ្នែកបច្ចេកទេសរបស់ប្រទេសអូស្ត្រាលី តាមរយៈ**កម្មវិធីភាពជាដៃគូកម្ពុជា-អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់** (CAPRED) ដែលបានដឹកនាំ សម្របសម្រួល និងរៀបចំផែនការអភិវឌ្ឍន៍ស្ថាប័ននេះ រហូតសម្រេចបានជោគជ័យ។

ជាមួយនឹងការដាក់ឱ្យអនុវត្តជាផ្លូវការនូវ **"ផែនការអភិវឌ្ឍន៍ស្ថាប័ន វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០២៦-២០២៨"** ខ្ញុំសូមស្នើថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកទាំងអស់របស់វិទ្យាស្ថានជាតិស្ថិតិ យកចិត្តទុកដាក់ និងចូលរួមអនុវត្តផែនការអភិវឌ្ឍន៍ស្ថាប័ននេះ ប្រកបដោយស្មារតីបុរេសកម្ម ការទទួលខុសត្រូវ ក្រមសីលធម៌វិជ្ជាជីវៈ និងភាពម្ចាស់ការខ្ពស់ ដើម្បីសម្រេចបាននូវលទ្ធផលតាមការរំពឹងទុក ដែលជាគុណប្រយោជន៍រួមសម្រាប់ស្ថាប័ន និងប្រទេសជាតិ។

ថ្ងៃព្រហស្បតិ៍ ១០រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២៦

**ប្រធានក្រុមប្រឹក្សាភិបាល**

**នៃវិទ្យាស្ថានជាតិស្ថិតិ**

**រិន ធីរៈ**

# ខ្លឹមសារសង្ខេប

វិទ្យាស្ថានជាតិស្ថិតិ ជាតួអង្គស្នូលនៃប្រព័ន្ធស្ថិតិកម្ពុជា ដែលមានមុខងារចម្បងក្នុងការដឹកនាំ សម្របសម្រួល លើការកសាងប្រព័ន្ធស្ថិតិរួមបញ្ចូលគ្នាតែមួយ ដែលបំពេញទៅដល់តម្រូវការនៃទិន្នន័យស្ថិតិ សម្រាប់ជាមូលដ្ឋានក្នុងការដាក់ចេញទិសដៅគោលនយោបាយ ការសម្រេចចិត្ត និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីគោលនយោបាយអភិវឌ្ឍន៍ជាតិ។ បន្ទាប់ពីការវិវត្តខ្លួនអស់ ជាច្រើនទសវត្សរ៍ វិទ្យាស្ថានជាតិស្ថិតិបានឈានដល់ដំណាក់កាលសំខាន់មួយ ដែលតម្រូវឱ្យមានការ ធ្វើទំនើបភាវូបនីយកម្មបន្ថែម តាមរយៈការដាក់ចេញនូវផែនការអភិវឌ្ឍន៍ស្ថាប័ន ដែលមានភាពគត់មត់ គ្រប់ជ្រុងជ្រោយ និងដោះស្រាយបាននូវបញ្ហាប្រឈមនានា។ ផែនការអភិវឌ្ឍន៍ស្ថាប័ន វិទ្យាស្ថាន ជាតិស្ថិតិ មានគោលបំណងផ្តល់ជាផែនទីបង្ហាញផ្លូវ ក្នុងការកែទម្រង់ និងការកសាងសមត្ថភាពនៃ ស្ថាប័ននេះ ដើម្បីឆ្លើយតបបានទៅនឹងតម្រូវការក្នុងការផលិត និងផ្សព្វផ្សាយទិន្នន័យស្ថិតិ ស្របតាម ទិសដៅគោលនយោបាយ និងចក្ខុវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍប្រព័ន្ធស្ថិតិជាតិ។

ផែនការអភិវឌ្ឍន៍ស្ថាប័ន វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០២៦-២០២៨ កំណត់នូវចក្ខុវិស័យ ប្រែក្លាយទៅជា **"ស្ថាប័នទំនើប និងមានសមត្ថភាពខ្ពស់ ក្នុងការផលិត និងចែករំលែកទិន្នន័យស្ថិតិ ប្រកបដោយគុណភាព គណនេយ្យភាព និងតម្លាភាព សំដៅលើកកម្ពស់ប្រព័ន្ធស្ថិតិជាតិមួយ ស្របតាម ឧត្តមានុវត្តន៍អន្តរជាតិ។"**

ដើម្បីឈានទៅសម្រេចចក្ខុវិស័យនេះ វិទ្យាស្ថានជាតិស្ថិតិ មានបេសកកម្មចម្បងក្នុងការប្រមូល ការចងក្រង ការកែច្នៃ ការវិភាគ និងការផ្សព្វផ្សាយទិន្នន័យស្ថិតិប្រកបដោយគុណភាព ភាពជឿជាក់ ទាន់ពេល និងនិរន្តរភាព ដើម្បីគាំទ្រដល់ការរៀបចំគោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍របស់ រាជរដ្ឋាភិបាល ក៏ដូចជាឆ្លើយតបទៅនឹងសេចក្តីត្រូវការទិន្នន័យស្ថិតិ របស់វិស័យឯកជន សហគមន៍ជាតិ និងអន្តរជាតិ និងសាធារណជន។ វិទ្យាស្ថានជាតិស្ថិតិ ប្រកាន់ខ្ជាប់គុណតម្លៃស្ថាប័ន ដែលមាន ភាពប្រទាក់ក្រឡា និងបំពេញគ្នាទៅវិញទៅមក រួមមាន គុណភាព ភាពជាអ្នកដឹកនាំ គណនេយ្យភាព សីលធម៌វិជ្ជាជីវៈ និងនវានុវត្តន៍ ដើម្បីកសាងស្ថាប័នមានសមត្ថភាពពេញលេញ និងជំរុញការ បំពេញការងារក្នុងជវភាពនៃប្រព័ន្ធតួអង្គតែមួយ។

**ផែនការអភិវឌ្ឍន៍ស្ថាប័ន វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០២៦-២០២៨** ដាក់ចេញនូវគោលដៅ ជាយុទ្ធសាស្ត្រ ចំនួន ៥ រួមមាន៖

(១). **ការពង្រឹងយន្តការស្ថាប័ន និងការសម្របសម្រួលប្រព័ន្ធស្ថិតិជាតិ** តាមរយៈការលើកកម្ពស់ អភិបាលកិច្ចផ្ទៃក្នុង ការពង្រឹងយន្តការសម្របសម្រួលប្រព័ន្ធស្ថិតិជាតិ និងការជំរុញភាព ជាដៃគូជាមួយគ្រប់ភាគីពាក់ព័ន្ធ

(២). **ការពង្រឹងការអនុវត្តមុខងារស្នូល និងការធានាគុណភាពទិន្នន័យស្ថិតិ** តាមរយៈការពង្រឹងការអនុវត្តតួនាទីភារកិច្ច ការធានាគុណភាពទិន្នន័យ និងការយកចិត្តទុកដាក់លើការផ្សព្វផ្សាយ

(៣). **ការអភិវឌ្ឍធនធានមនុស្ស** តាមរយៈការលើកកម្ពស់ភាពជាអ្នកដឹកនាំ ការគ្រប់គ្រងធនធានមនុស្ស និងការបណ្ដុះបណ្ដាលជំនាញ

(៤). **ការរៀបចំទីកន្លែងធ្វើការសមរម្យ និងវប្បធម៌ការងារវិជ្ជមាន** តាមរយៈការកែលម្អបរិស្ថានការងារ ការលើកកម្ពស់វប្បធម៌ការងារ និងការរៀបចំយន្តការលើកទឹកចិត្តសមស្រប

(៥). **ការកសាងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់ជ្រុងជ្រោយ** តាមរយៈការអភិវឌ្ឍប្រព័ន្ធឌីជីថលសម្រាប់ការគ្រប់គ្រងទិន្នន័យ ការធ្វើឌីជីថលូនីយកម្មរំហូរការងារ និងការធានាសន្តិសុខទិន្នន័យ។

ផែនការអភិវឌ្ឍន៍ស្ថាប័នវិទ្យាស្ថានជាតិស្ថិតិ ដាក់ចេញនូវ**ផែនការសកម្មភាពគន្លឹះ សរុបចំនួន ៧៩** ដោយចេញជា ៥ផ្នែក សម្រាប់រយៈពេល ៣ ឆ្នាំ ចាប់ពីឆ្នាំ២០២៦ ដល់ឆ្នាំ២០២៨ ។ សកម្មភាពតាមផ្នែក រួមមាន ផ្នែកការពង្រឹងយន្តការស្ថាប័ន និងការសម្របសម្រួលប្រព័ន្ធស្ថិតិជាតិ មាន ១៧ សកម្មភាព, ផ្នែកការពង្រឹងការអនុវត្តមុខងារស្នូល និងការធានាគុណភាពទិន្នន័យស្ថិតិ មាន ១៨ សកម្មភាព, ផ្នែកការអភិវឌ្ឍន៍ធនធានមនុស្ស មាន ១៦ សកម្មភាព, ផ្នែកការរៀបចំទីកន្លែងធ្វើការសមរម្យ និងវប្បធម៌ការងារវិជ្ជមាន មាន ១៥ សកម្មភាពគន្លឹះ និងផ្នែកការកសាងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់ជ្រុងជ្រោយ មាន ១៣ សកម្មភាព។ សកម្មភាពគន្លឹះតាមឆ្នាំ រួមមាន ឆ្នាំ២០២៦ មានចំនួន ៤៥សកម្មភាព, ឆ្នាំ២០២៧ មានចំនួន ៥៩ សកម្មភាព និងឆ្នាំ២០២៨ មានចំនួន ៥២ សកម្មភាព។

ដើម្បីធានានូវភាពជោគជ័យ ក្នុងការអនុវត្តនូវផែនការអភិវឌ្ឍន៍ស្ថាប័ននេះ យន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ត្រូវបានគិតគូរជាប្រព័ន្ធ ដែលស្ថិតក្រោមការដឹកនាំផ្ទាល់ដោយក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានជាតិស្ថិតិ ដើម្បីពិនិត្យ និងតម្រង់ទិសជាប្រចាំលើវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពគន្លឹះ បញ្ហាប្រឈម និងការដាក់ចេញវិធានការគន្លឹះចាំបាច់បន្ថែម។

# មាតិកា


**អារម្ភកថា** ........ i

**ខ្លឹមសារសង្ខេប** ........ iii

**មាតិកា** ........ v

**១. សេចក្តីផ្តើម** ........ ១

១.១. បរិការណ៍រួម ........ ១

១.២. គោលបំណង ........ ២

**២. ប្រព័ន្ធស្ថិតិកម្ពុជា និងស្ថានភាពវិទ្យាស្ថានជាតិស្ថិតិ** ........ ៣

២.១. ប្រព័ន្ធស្ថិតិកម្ពុជា ........ ៣

២.២. ក្របខ័ណ្ឌគតិយុត្ត និងគោលនយោបាយក្នុងវិស័យស្ថិតិ ........ ៤

២.៣. យន្តការសម្របសម្រួលប្រព័ន្ធស្ថិតិជាតិ ........ ៤

២.៤. ប្រវត្តិនៃការកកើតអង្គភាពស្ថិតិ ........ ៥

២.៥. ការវិវត្តចុងក្រោយនៃវិទ្យាស្ថានជាតិស្ថិតិ ........ ៥

២.៥.១. រចនាសម្ព័ន្ធចាត់តាំងនៃវិទ្យាស្ថានជាតិស្ថិតិបច្ចុប្បន្ន ........ ៦

២.៥.២. ធនធានមនុស្ស ........ ៧

២.៥.៣. ធនធានហិរញ្ញវត្ថុ ........ ៨

២.៥.៤. សម្ភារៈបរិក្ខារ និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ........ ៨

២.៦. សមិទ្ធផលសំខាន់ៗ ........ ៩

២.៧. បញ្ហាប្រឈម ........ ៩

**៣. ទិសដៅនៃការអភិវឌ្ឍស្ថាប័នវិទ្យាស្ថានជាតិស្ថិតិ** ........ ១១

៣.១. ទស្សនាទានរួម ........ ១១

៣.២. កត្តាជំរុញ ........ ១២

**៤. ផែនការអភិវឌ្ឍន៍ស្ថាប័ន** ........ ១៣

៤.១. ចក្ខុវិស័យ ........ ១៣

៤.២. បេសកកម្ម ........ ១៣

៤.៣. គុណតម្លៃស្ថាប័ន ........ ១៣

៤.៤. គោលដៅជាយុទ្ធសាស្ត្រ ........ ១៥

៤.៤.១. ការពង្រឹងយន្តការស្ថាប័ន និងការសម្របសម្រួលប្រព័ន្ធស្ថិតិជាតិ ........ ១៥

៤.៤.២. ការពង្រឹងការអនុវត្តមុខងារស្នូល និងការធានាគុណភាពទិន្នន័យស្ថិតិ ........ ១៥

៤.៤.៣. ការអភិវឌ្ឍន៍ធនធានមនុស្ស ........ ១៦

៤.៤.៤. ការរៀបចំទីកន្លែងធ្វើការសមរម្យ និងវប្បធម៌ការងារវិជ្ជមាន ........ ១៦

៤.៤.៥. ការកសាងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់ជ្រុងជ្រោយ ........ ១៧

៤.៥. ផែនការសកម្មភាពគន្លឹះ ........ ១៨

**៥. ការអនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ........ ១៩**

៥.១. យន្តការអនុវត្ត ........ ១៩

៥.១.១. តួអង្គពាក់ព័ន្ធ និងតួនាទីភារកិច្ច ........ ១៩

៥.១.២. ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ........ ២០

៥.២. ធនធានគាំទ្រ ........ ២០

៥.៣. ហានិភ័យនៃការអនុវត្ត ........ ២១

**៦. សេចក្តីសន្និដ្ឋាន ........ ២២**

**ឧបសម្ព័ន្ធ៖ ផែនការសកម្មភាពគន្លឹះ ........ ២៣**

# ១. សេចក្តីផ្តើម

## ១.១. បរិការណ៍រួម

ប្រព័ន្ធស្ថិតិរឹងមាំ និងប្រកបដោយប្រសិទ្ធភាព ដើរតួនាទីយ៉ាងសំខាន់ ដែលជាមូលដ្ឋានក្នុងការលើកកម្ពស់អភិបាលកិច្ច និងការធានាគណនេយ្យភាពសមិទ្ធកម្មរបស់រដ្ឋាភិបាល។ ទិន្នន័យស្ថិតិប្រកបដោយគុណភាព អាចឱ្យរដ្ឋាភិបាលធ្វើការសម្រេចចិត្ត ដោយផ្អែកលើព័ត៌មានគ្រប់ជ្រុងជ្រោយ ក្នុងការកំណត់ទិសដៅគោលនយោបាយ ការដាក់ចេញកម្មវិធីអភិវឌ្ឍន៍ និងជម្រើសវិធានការសមស្រប ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនានា និងការរៀបចំយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃការអនុវត្ត ប្រកបដោយប្រសិទ្ធភាព។

ទន្ទឹមនឹងការបន្តវិវឌ្ឍនៃប្រព័ន្ធទិន្នន័យស្ថិតិសកល ការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាដូចជាការឈានឡើងនៃទិន្នន័យធំ និងបញ្ញាសិប្បនិម្មិត ជាដើម បាននាំមកនូវបត់ផ្លាស់ប្តូរលើការផលិត និងការប្រើប្រាស់ទិន្នន័យស្ថិតិ។ ការណ៍នេះ ទាមទារឱ្យរដ្ឋាភិបាលនៃប្រទេសនីមួយៗ ចាំបាច់ធ្វើទំនើបកម្ម និងកែលម្អប្រព័ន្ធស្ថិតិជាតិ ព្រមទាំងជំរុញឱ្យមានការផ្លាស់ប្តូរ និងសម្របខ្លួនពីស្ថាប័នស្ថិតិកណ្តាលនៃប្រទេសនីមួយៗ តាមរយៈការកែលម្អស្តង់ដា និងវិធីសាស្ត្រ ការកសាងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាដែលកាន់តែមានប្រសិទ្ធភាពខ្ពស់ ព្រមជាមួយនឹងការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពធនធានមនុស្ស ដើម្បីធានាថាស្ថាប័នស្ថិតិ អាចដើរទាន់ និងចាប់យកអត្ថប្រយោជន៍ជាអតិបរិមាពីរបត់ថ្មីនេះ។

**រូបភាពទី១៖** និន្នាការ និងកាលានុវត្តភាពពីការធ្វើបរិវត្តកម្មប្រព័ន្ធស្ថិតិ



សម្រាប់កម្ពុជា រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដោយមានការកែទម្រង់ និងការពង្រឹងអភិបាលកិច្ច ជាស្នូលនៃយុទ្ធសាស្ត្រ។ ក្នុងបរិការណ៍នេះ, រាជរដ្ឋាភិបាលកម្ពុជាមើលឃើញពីសារៈសំខាន់នៃការពង្រឹងប្រព័ន្ធទិន្នន័យស្ថិតិ ដែលជាសមាសធាតុមិនអាចខ្វះបាន ក្នុងការរៀបចំរបៀបវារៈអភិវឌ្ឍន៍ ការតាមដានការវិវឌ្ឍនៃស្ថានភាពសង្គម-សេដ្ឋកិច្ច ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីគោលនយោបាយ ព្រមជាមួយការដាក់ចេញវិធានការឆ្លើយតបទៅនឹងបញ្ហាប្រឈមនានា ក្នុងបរិការណ៍នៃការប្រែប្រួលនិម្មាបនកម្មសង្គម-សេដ្ឋកិច្ច ក្នុងប្រទេស តំបន់ និងសកល។ ទន្ទឹមនេះ ស្របពេលដែលកម្ពុជាកំពុងឈានឆ្ពោះទៅសម្រេចចក្ខុវិស័យឆ្នាំ២០៥០ ក្នុងការប្រែក្លាយទៅជាប្រទេសដែលមានចំណូលខ្ពស់ កម្ពុជាមានភាពចាំបាច់ ក្នុងការពង្រីកវិសាលភាពទិន្នន័យស្ថិតិផ្លូវការ ដើម្បីគ្របដណ្តប់នូវសូចនាករអភិវឌ្ឍន៍ និងនិន្នាការសកលថ្មីៗបន្ថែមទៀត ដូចជា រង្វាស់សេដ្ឋកិច្ចឌីជីថល ទិន្នន័យធំ និងទិន្នន័យទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ជាដើម។ ការសម្រេចបាននូវគោលដៅទាំងនេះ ទាមទារនូវការបង្កើននូវប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃប្រព័ន្ធស្ថិតិជាតិជារួម ព្រមទាំងការកសាងសមត្ថភាពបច្ចេកទេស និងការអភិវឌ្ឍបន្ថែមទៀតនៅក្នុងវិទ្យាស្ថានជាតិស្ថិតិ ដែលជាស្ថាប័នស្នូលនៃប្រព័ន្ធស្ថិតិជាតិ។

## ១.២. គោលបំណង

ទោះបីជានាពេលកន្លងមក វិទ្យាស្ថានជាតិស្ថិតិសម្រេចបាននូវសមិទ្ធផលផ្លែផ្កាជាច្រើន ក្នុងការផលិត និងផ្សព្វផ្សាយស្ថិតិផ្លូវការ ស្ថាប័ននេះបន្តប្រឈមនឹងបញ្ហាមួយចំនួន ដែលរារាំងដល់ការបំពេញទៅតាមតម្រូវការ នៃការប្រើប្រាស់ទិន្នន័យស្ថិតិ ព្រមទាំងការធានានូវប្រសិទ្ធភាពក្នុងការសម្របសម្រួលប្រព័ន្ធស្ថិតិជាតិ។ បញ្ហាប្រឈមចម្បងៗពាក់ព័ន្ធនឹងយន្តការស្ថាប័ន និងស័ក្តិសិទ្ធភាពប្រតិបត្តិការ បានជះឥទ្ធិពលដល់ការធានាគុណភាព ភាពត្រឹមត្រូវ និងភាពទាន់ពេលនៃការផលិត និងផ្សព្វផ្សាយទិន្នន័យស្ថិតិ ព្រមទាំងបង្អាក់ដល់ការទំនើបកម្មស្ថាប័ន ជាពិសេសការកសាងមូលធនមនុស្ស។

ផែនការអភិវឌ្ឍន៍ស្ថាប័នវិទ្យាស្ថានជាតិស្ថិតិ មានគោលបំណង ផ្តល់ជាផែនទីបង្ហាញផ្លូវក្នុងការកែទម្រង់ និងការកសាងសមត្ថភាពនៃស្ថាប័ននេះ ដើម្បីឆ្លើយតបបានទៅនឹងតម្រូវការក្នុងការផលិតទិន្នន័យស្ថិតិ និងស្របតាមទិសដៅគោលនយោបាយរបស់រាជរដ្ឋាភិបាល និងជាពិសេសប្រែក្លាយស្ថាប័ននេះ ទៅជាស្ថាប័នដើរតួនាទីស្នូលរបស់រាជរដ្ឋាភិបាល លើការប្រមូល និងវិភាគទិន្នន័យសម្រាប់ប្រទេសទាំងមូល។

# ២. ប្រព័ន្ធស្ថិតិកម្ពុជា និងស្ថានភាពវិទ្យាស្ថានជាតិស្ថិតិ

## ២.១. ប្រព័ន្ធស្ថិតិកម្ពុជា

អស់រយៈពេលជាច្រើនទសវត្សរ៍ កម្ពុជាបានឆ្លងកាត់នូវដំណើរវិវត្តជាបន្តបន្ទាប់ ក្នុងការកសាងប្រព័ន្ធស្ថិតិជាតិ ដោយចាប់ផ្តើមពីការប្រមូលចងក្រងទិន្នន័យស្ថិតិមូលដ្ឋាន នៅតាមស្ថាប័ន និងអង្គភាពនីមួយៗ ដាច់ដោយឡែកពីគ្នា រហូតដល់ការអភិវឌ្ឍបានជាប្រព័ន្ធស្ថិតិជាតិមួយ ដែលមានលក្ខណៈជាប្រព័ន្ធរួមបញ្ចូល ឬប្រព័ន្ធសមាហរណកម្ម។ ប្រព័ន្ធស្ថិតិជាតិនេះ ធ្វើការប្រមូលផ្តុំ បន្សុំ និងធ្វើឱ្យមានសង្គតិភាព ទិន្នន័យស្ថិតិពីគ្រប់ភាគីពាក់ព័ន្ធ ដោយមានវិទ្យាស្ថានជាតិស្ថិតិដើរតួនាទីជាស្ថាប័នស្នូល ក្នុងការសម្របសម្រួល ប្រមូល ចងក្រង វិភាគ និងផ្សព្វផ្សាយស្ថិតិផ្លូវការរបស់ជាតិ និងបណ្តាក្រសួង ស្ថាប័ន ជាអ្នកចងក្រង និងផលិតទិន្នន័យទៅតាមវិស័យ និងអាណត្តិកិច្ចរបស់ខ្លួន។

**រូបភាពទី២៖** គំនូសបំព្រួញនៃប្រព័ន្ធស្ថិតិរួមបញ្ចូល ឬប្រព័ន្ធស្ថិតិសមាហរណកម្ម




មុខងារចម្បងៗរបស់វិទ្យាស្ថានជាតិស្ថិតិ មានដូចជា ការរៀបចំគោលនយោបាយស្ថិតិផ្លូវការ ការកំណត់ស្តង់ដាររួមសម្រាប់ការប្រមូល និងផលិតទិន្នន័យស្ថិតិ ដើម្បីធានាសង្គតិភាពក្នុងការប្រើប្រាស់ ការផលិតស្ថិតិផ្លូវការសំខាន់ៗ តាមរយៈជំរឿន និងអង្កេត ការចងក្រងស្ថិតិគណនេយ្យជាតិ និងសន្ទស្សន៍ថ្លៃ និងស្ថិតិតាមវិស័យសំខាន់ៗផ្សេងទៀត ព្រមទាំងការសម្របសម្រួលការប្រមូលផ្តុំទិន្នន័យរដ្ឋបាលពីគ្រប់ក្រសួង ស្ថាប័ន សម្រាប់ការចងក្រង និងផ្សព្វផ្សាយជាសាធារណៈ។ ជាមួយនឹងមុខងារទាំងនេះ បេសកកម្មចម្បងរបស់វិទ្យាស្ថានជាតិស្ថិតិ គឺការធានាគុណភាព ភាពគ្រប់ជ្រុងជ្រោយ និងភាពទាន់ពេលនៃការផលិតទិន្នន័យស្ថិតិ ដើម្បីឆ្លើយតបទៅតាមតម្រូវការនៃការប្រើប្រាស់ទិន្នន័យស្ថិតិ។

## ២.២. ក្របខណ្ឌគតិយុត្ត និងគោលនយោបាយក្នុងវិស័យស្ថិតិ

ប្រព័ន្ធស្ថិតិកម្ពុជា ត្រូវបានរៀបចំ និងដំណើរការ ដោយអនុលោមទៅតាមច្បាប់ស្តីពីស្ថិតិ។ ច្បាប់ស្តីពីស្ថិតិ មានវិសាលភាពអនុវត្តលើរាល់សកម្មភាពស្ថិតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយចែងអំពីគោលការណ៍នៃការអភិវឌ្ឍស្ថិតិ ដោយត្រូវឈរលើមូលដ្ឋាននៃភាពត្រឹមត្រូវ ភាពឯករាជ្យ ភាពសត្យានុម័ត ភាពគួរទុកចិត្តបាន ភាពសំខាន់ និងភាពទាន់ពេលវេលា ស្របតាមគោលការណ៍គ្រឹះនៃស្ថិតិផ្លូវការរបស់អង្គការសហប្រជាជាតិ និងប្រព័ន្ធស្ថិតិរបស់សហគមន៍អាស៊ាន។ ច្បាប់នេះចែងផងដែរអំពីយន្តការស្ថាប័ននៃប្រព័ន្ធស្ថិតិជាតិ ការប្រមូលទិន្នន័យស្ថិតិ ព្រមទាំងការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ។ ការរៀបចំ និងកិច្ចដំណើរការនៃប្រព័ន្ធស្ថិតិកម្ពុជា ត្រូវបានកំណត់លម្អិតបន្ថែម នៅក្នុងលិខិតបទដ្ឋានសំខាន់ៗដូចជា អនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការនៃប្រព័ន្ធស្ថិតិជាតិ និងអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង។

គោលនយោបាយស្ថិតិផ្លូវការ គឺជាផែនទីបង្ហាញផ្លូវក្នុងការអភិវឌ្ឍប្រព័ន្ធស្ថិតិកម្ពុជា ដែលជាឯកសារគោលនយោបាយរយៈពេល១០ឆ្នាំ ដើម្បីកំណត់នូវចក្ខុវិស័យ និងអាទិភាពរយៈពេលវែង ក្នុងការកសាងប្រព័ន្ធស្ថិតិមួយដែលទំនើប និងមានសមាហរណកម្មពេញលេញ។ ទន្ទឹមនេះ យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ គឺជាផែនការរយៈពេលមធ្យមស្របតាមអាណត្តិរបស់រាជរដ្ឋាភិបាល ដែលប្រែក្លាយចក្ខុវិស័យនៃគោលនយោបាយស្ថិតិផ្លូវការ ទៅជាផែនការការងារលម្អិត ដោយកំណត់គោលដៅ ក្របខ័ណ្ឌពេលវេលាជាក់លាក់ សម្រាប់វិទ្យាស្ថានជាតិស្ថិតិ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ យកទៅអនុវត្ត។

## ២.៣. យន្តការសម្របសម្រួលប្រព័ន្ធស្ថិតិជាតិ

ច្បាប់ស្តីពីស្ថិតិ បានកំណត់យន្តការសម្របសម្រួលប្រព័ន្ធស្ថិតិជាតិ តាមរយៈការបង្កើតឡើងនូវក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិ។ ក្រុមប្រឹក្សាស្ថិតិ ជាយន្តការសម្របសម្រួលកម្រិតនយោបាយ ដែលមានតួនាទីតម្រង់ទិសលើការរៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការងារស្ថិតិ គោលនយោបាយស្ថិតិផ្លូវការ និងយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ ការកំណត់មុខសញ្ញា និងតម្រូវការស្ថិតិផ្លូវការ កាលបរិច្ឆេទនៃការធ្វើជំរឿន អង្កេត ទិសដៅយុទ្ធសាស្ត្រ និងអាទិភាពការងារក្នុងវិស័យស្ថិតិ។ វិទ្យាស្ថានជាតិស្ថិតិមានតួនាទីសំខាន់ ក្នុងយន្តការសម្របសម្រួលនេះ ដោយមានមុខងារជាលេខាធិការដ្ឋានជូនក្រុមប្រឹក្សាស្ថិតិ។

ទន្ទឹមនេះ នាយកនៃវិទ្យាស្ថានជាតិស្ថិតិ គឺជាប្រធានគណៈកម្មាធិការសម្របសម្រួលស្ថិតិ ដែលជាយន្តការសម្របសម្រួលកម្រិតបច្ចេកទេស អន្តរស្ថាប័ន ដើម្បីជំរុញការធ្វើសមាហរណកម្មប្រព័ន្ធស្ថិតិជាតិតែមួយ តាមរយៈការសម្របសម្រួល និងសហប្រតិបត្តិការ ប្រកបដោយប្រសិទ្ធភាពរវាងវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង ការរៀបចំកិច្ចព្រមព្រៀងសហប្រតិបត្តិការ និងកិច្ចសម្របសម្រួលរវាងក្រសួង-ស្ថាប័ន អំពីការផ្លាស់ប្តូរទិន្នន័យ ការបង្កើតក្រុមការងារបច្ចេកទេសស្ថិតិ ការពិនិត្យ និងដាក់ឱ្យប្រើប្រាស់ចំណាត់ថ្នាក់ និងបទដ្ឋានស្ថិតិ និងការដាក់ចេញផែនការការងារ និងផែនការអភិវឌ្ឍន៍ធនធានមនុស្សលើវិស័យស្ថិតិ ជាដើម។

## ២.៤. ប្រវត្តិនៃការកកើតអង្គភាពស្ថិតិ

អង្គភាពស្ថិតិរបស់កម្ពុជា ត្រូវបានរៀបចំឡើងដំបូង នៅក្នុងសម័យអាណានិគមនិយមបារាំង នាឆ្នាំ១៩៤៨ ក្រោមឈ្មោះជានាយកដ្ឋានស្ថិតិនៃកម្ពុជា។ ក្នុងដំណាក់កាលដែលកម្ពុជា ទើបតែទទួលបានឯករាជ្យភាពពេញលេញ ពីអាណានិគមនិយមបារាំង កម្ពុជាបានរៀបចំកែទម្រង់ស្ថាប័នស្ថិតិជាថ្មីឡើងវិញ នៅក្នុងឆ្នាំ១៩៥៣ ដោយផ្លាស់ប្ដូរឈ្មោះទៅជា នាយកដ្ឋានស្ថិតិ និងពិនិត្យសេដ្ឋកិច្ច និងមានមុខងារសំខាន់ក្នុងការប្រមូល និងគ្រប់គ្រងទិន្នន័យស្ថិតិចាំបាច់នានា ដែលបម្រើដល់ការកសាងមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចជាតិ។ ក្នុងឆ្នាំ១៩៦៣ អង្គភាពនេះត្រូវបានប្រែក្លាយទៅជាវិទ្យាស្ថានជាតិស្ថិតិ និងការស្រាវជ្រាវសេដ្ឋកិច្ច ដែលការផ្លាស់ប្ដូរនេះបានបង្ហាញពីតម្រូវការកាន់តែខ្ពស់នៃការប្រើប្រាស់ទិន្នន័យស្ថិតិ សម្រាប់ការសិក្សាស្រាវជ្រាវ និងបម្រើដល់ការដាក់ចេញទិសដៅគោលនយោបាយសង្គម-សេដ្ឋកិច្ច នាសម័យនោះ។

ក្នុងឆ្នាំ១៩៧៥ ស្ថាប័នស្ថិតិ ព្រមទាំងស្ថាប័នរដ្ឋសំខាន់ៗផ្សេងទៀត ត្រូវបានរបបខ្មែរក្រហមបំផ្លាញចោលទាំងស្រុង ដែលនាំមកនូវការបន្ទុចបង្អាក់ដល់ដំណើរវិវត្តរីកចម្រើន នៃកិច្ចការប្រមូល និងផលិតទិន្នន័យស្ថិតិនៅកម្ពុជា។ បន្ទាប់ពីបានរួចផុតពីរបបប្រល័យពូជសាសន៍ ក្នុងឆ្នាំ១៩៧៩ កម្ពុជាបានចាប់ផ្ដើមស្ដារឡើងវិញនូវប្រព័ន្ធរដ្ឋបាលសាធារណៈរបស់ខ្លួន និងបង្កើតនូវស្ថាប័នស្ថិតិជាតិនៅក្រោមរចនាសម្ព័ន្ធរបស់ក្រសួងហិរញ្ញវត្ថុ ដោយមានឈ្មោះជានាយកដ្ឋានស្ថិតិ។ នាយកដ្ឋានស្ថិតិនេះ ត្រូវបានផ្ទេរមកស្ថិតក្រោមរចនាសម្ព័ន្ធរបស់ក្រសួងផែនការ នៅឆ្នាំ១៩៨១ ដើម្បីអនុវត្តការប្រមូលទិន្នន័យស្ថិតិនានា ដែលគាំទ្រដល់ការរៀបចំផែនការអភិវឌ្ឍន៍ ដូចជាការអង្កេត និងប៉ាន់ស្មានចំនួនប្រជាជន ជាដើម។

ទសវត្សឆ្នាំ១៩៩០ គឺជាចំណុចរបត់មួយ នៅពេលដែលប្រទេសកម្ពុជាបានផ្លាស់ប្ដូរទៅរកសេដ្ឋកិច្ចទីផ្សារ ដែលកម្ពុជាមានតម្រូវការទិន្នន័យស្ថិតិកាន់តែច្រើនឡើង សម្រាប់ការតាមដានស្ថានភាពសេដ្ឋកិច្ចរបស់ខ្លួន និងគាំទ្រដល់ការរៀបចំគោលនយោបាយអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច។ ក្នុងបរិការណ៍នេះ ចាប់ពីឆ្នាំ២០០៥ រហូតដល់ឆ្នាំ២០២៤ វិទ្យាស្ថានជាតិស្ថិតិ ត្រូវបានដំឡើងកម្រិតស្មើអគ្គនាយកដ្ឋាន ដោយបន្តស្ថិតនៅក្រោមរចនាសម្ព័ន្ធនៃក្រសួងផែនការ។

## ២.៥. ការវិវត្តចុងក្រោយនៃវិទ្យាស្ថានជាតិស្ថិតិ

តាមរយៈអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៥ វិទ្យាស្ថានជាតិស្ថិតិត្រូវបានប្រែក្លាយជាគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ដែលការប្រែក្លាយនេះបានបង្កើននូវស្វ័យភាព និងភាពជាម្ចាស់ ដល់វិទ្យាស្ថានជាតិស្ថិតិក្នុងកិច្ចប្រតិបត្តិការ ទាំងផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងការគ្រប់គ្រងធនធានមនុស្ស។ ក្នុងនាមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល វិទ្យាស្ថានជាតិស្ថិតិ ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដែលមានសមាសភាពចំនួន ១១រូប ជាតំណាង ពីក្រសួង-ស្ថាប័នពាក់ព័ន្ធសំខាន់ៗ ដែលជាអង្គការដឹកនាំខ្ពស់បំផុត និងមានបេសកកម្ម តម្រង់ទិសការអនុវត្ត និងត្រួតពិនិត្យសកម្មភាពការងាររបស់វិទ្យាស្ថានជាតិស្ថិតិ ។

## ២.៥.១. រចនាសម្ព័ន្ធចាត់តាំងនៃវិទ្យាស្ថានជាតិស្ថិតិបច្ចុប្បន្ន

បន្ទាប់ពីត្រូវបានប្រែក្លាយទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល រចនាសម្ព័ន្ធចាត់តាំងនៃវិទ្យាស្ថានជាតិស្ថិតិ ត្រូវបានរៀបចំកែសម្រួលឡើងវិញ និងសម្រួចតួនាទី និងភារកិច្ច របស់នាយកដ្ឋាននីមួយៗ ឱ្យស្របនឹងឧត្តមានុវត្តន៍ជាអន្តរជាតិ និងស្ថានភាពជាក់ស្តែងនៃស្ថាប័ន។ រចនាសម្ព័ន្ធថ្មីនេះ រួមបញ្ចូលនូវនាយកដ្ឋានជំនាញចំនួន ៨ រួមមាន នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នាយកដ្ឋានគោលនយោបាយ ស្តង់ដា និងសហប្រតិបត្តិការស្ថិតិ នាយកដ្ឋានគ្រប់គ្រងទិន្នន័យ និងបច្ចេកវិទ្យាព័ត៌មាន នាយកដ្ឋានស្ថិតិសេដ្ឋកិច្ច នាយកដ្ឋានស្ថិតិសង្គមកិច្ច នាយកដ្ឋានស្ថិតិប្រជាសាស្ត្រ និងជំរឿនប្រជាជន នាយកដ្ឋានស្ថិតិគណនេយ្យជាតិ និងនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ។

**រូបភាពទី៣៖** រចនាសម្ព័ន្ធនៃវិទ្យាស្ថានជាតិស្ថិតិ




**នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ** ជានាយកដ្ឋានថ្មី សម្រាប់ការបំពេញប្រតិបត្តិការស្របតាមការផ្លាស់ប្តូរជាគ្រឹះស្ថានសាធារណៈរដ្ឋបាល លើការគ្រប់គ្រងកិច្ចការរដ្ឋបាល ហិរញ្ញវត្ថុ ធនធានមនុស្ស និងទំនាក់ទំនងសាធារណៈ ដែលជាមុខងារដ៏ចម្បងមួយរបស់វិទ្យាស្ថានជាតិស្ថិតិ។ **នាយកដ្ឋានគោលនយោបាយ ស្តង់ដា និងសហប្រតិបត្តិការស្ថិតិ** ទទួលបន្ទុកលើការរៀបចំលិខិតបទដ្ឋានគតិយុត្ត

និងគោលនយោបាយស្ថិតិផ្លូវការ ការសម្របសម្រួលជាមួយស្ថាប័នជាតិ និងអន្តរជាតិ ដើម្បីកៀរគរកិច្ចសហប្រតិបត្តិការ ការរៀបចំ ចងក្រងវិធីសាស្ត្របច្ចេកទេស ព្រមទាំងការដាក់ចេញនូវចំណាត់ថ្នាក់ស្តង់ដាស្ថិតិ ដើម្បីធានានូវភាពត្រឹមត្រូវនៃការរៀបចំចងក្រងទិន្នន័យស្ថិតិ ព្រមទាំងសង្គតិភាពក្នុងការប្រើប្រាស់។ នាយកដ្ឋាននេះ មានតួនាទីជាលេខាធិការដ្ឋានជូនក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មការសម្របសម្រួលស្ថិតិ ដែលជាយន្តការកម្រិតខ្ពស់បំផុត ក្នុងការតម្រង់ទិសការអភិវឌ្ឍប្រព័ន្ធស្ថិតិជាតិ។

**នាយកដ្ឋានស្ថិតិគណនេយ្យជាតិ** ដើរតួនាទីសំខាន់ក្នុងការចងក្រងស្ថិតិគណនេយ្យជាតិ ស្ថិតិថ្លៃ អតិផរណា ព្រមទាំងទិន្នន័យម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗផ្សេងទៀត ដែលជាមូលដ្ឋានសំខាន់ក្នុងការវិភាគ និងវាយតម្លៃស្ថានភាពសេដ្ឋកិច្ច។ **នាយកដ្ឋានស្ថិតិសេដ្ឋកិច្ច** មានភារកិច្ចក្នុងការដឹកនាំការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ព្រមទាំងចងក្រង ប្រមូលទិន្នន័យស្ថិតិសំខាន់ៗ ដូចជាទិន្នន័យកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្មអន្តរជាតិ វិនិយោគ សំណង់ ទូរគមនាគមន៍ ដឹកជញ្ជូន ទេសចរណ៍ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាដើម។ **នាយកដ្ឋានស្ថិតិប្រជាសាស្ត្រ និងជំរឿនប្រជាជន** ទទួលខុសត្រូវក្នុងការធ្វើជំរឿនប្រជាជន បង្កើតការព្យាករចំនួនប្រជាជន ចងក្រងទិន្នន័យសុខភាព និងស្ថិតិអត្រានុកូលដ្ឋាន ជាដើម។ **នាយកដ្ឋានស្ថិតិសង្គមកិច្ច** ផ្តោតលើអង្កេតកម្លាំងពលកម្ម ស្ថិតិអប់រំ យុវជន និងកីឡា ស្ថិតិសុខាភិបាល ស្ថិតិពិការភាព ស្ថិតិការងារ ស្ថិតិវប្បធម៌ ព័ត៌មាន និងអង្កេតការប្រើប្រាស់ពេលវេលា ជាដើម។ ទិន្នន័យមូលដ្ឋានឃុំ សង្កាត់ និងទិន្នន័យរដ្ឋបាលមន្ទីរ អង្គភាព ត្រូវប្រមូល និងចងក្រង សម្រាប់កម្រិតថ្នាក់ក្រោមជាតិ ដោយ**នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ** ដើម្បីធានានូវវិសាលភាពគ្របដណ្តប់នៃស្ថិតិផ្លូវការ និងភាពសម្បូរបែបនៃស្ថិតិ។

**នាយកដ្ឋានគ្រប់គ្រងទិន្នន័យ និងបច្ចេកវិទ្យាព័ត៌មាន** មានតួនាទីគាំទ្រដល់កិច្ចដំណើរការ នៃការប្រមូល ចងក្រង និងផ្សព្វផ្សាយទិន្នន័យស្ថិតិ ជារួម។ នាយកដ្ឋាននេះ មានមុខងារក្នុងការគ្រប់គ្រងទិន្នន័យ បណ្តាញរចនាសម្ព័ន្ធបច្ចេកវិទ្យា អភិវឌ្ឍន៍កម្មវិធី បញ្ចូលទិន្នន័យប្រមូលទិន្នន័យ ព្រមទាំងគ្រប់គ្រងលើការបញ្ជូន ផ្ទេរ ទទួលទិន្នន័យ និងផ្សព្វផ្សាយលើគេហទំព័រ ការផ្តល់សេវាបណ្ណាល័យ និងធ្វើការផ្តល់សេវាផ្ទាល់សម្រាប់អ្នកប្រើប្រាស់។

## ២.៥.២. ធនធានមនុស្ស

ស្របតាមវិសាលភាពនៃមុខងារ និងភារកិច្ចដែលមានជាធរមាន វិទ្យាស្ថានជាតិស្ថិតិមានមន្ត្រីចំនួន ៤៨៥ នាក់ គិតត្រឹមដំណាច់ឆ្នាំ២០២៥។ ក្នុងនោះ មន្ត្រីភាគច្រើនមានគុណវុឌ្ឍិកម្រិតសញ្ញាបត្រខ្ពស់ ដែលរួមមាន កម្រិតបរិញ្ញាបត្រ ៧៣,៨% និងបរិញ្ញាបត្រជាន់ខ្ពស់ ១៤,៧% ។ ក្នុងចំណោមមន្ត្រីទាំងនេះ ប្រមាណ ១៧,៧% ជាអ្នកមានជំនាញផ្នែកសេដ្ឋកិច្ច ស្ថិតិ និងផែនការ ដែលជាជំនាញពាក់ព័ន្ធផ្ទាល់ ខណៈប្រមាណ ៦១,៧% ជាអ្នកដែលមានជំនាញពាក់ព័ន្ធបន្ទាប់ និងជំនាញគាំទ្រ ដូចជាគ្រប់គ្រងធុរកិច្ច គណនេយ្យ ហិរញ្ញវត្ថុ ច្បាប់ និងរដ្ឋបាលសាធារណៈ និងជំនាញបច្ចេកវិទ្យាព័ត៌មាន ជាដើម។

### ២.៥.៣. ធនធានហិរញ្ញវត្ថុ

វិទ្យាស្ថានជាតិស្ថិតិ ទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុពីប្រភពសំខាន់ៗ ចំនួន៤ រួមមានៈ ការរិភាជថវិការដ្ឋ ជំនួយពីដៃគូអភិវឌ្ឍ ការឧបត្ថម្ភធនពីអ្នកគាំទ្រ និងប្រាក់ចំណូលផ្សេងទៀតពីប្រភពស្របច្បាប់។ ការផ្តល់ធនធាននេះ បានគាំទ្រដល់ការចំណាយចម្បងចំនួន៣ គឺការចំណាយលើបន្ទុកបុគ្គលិក ការចំណាយលើប្រតិបត្តិការទូទៅ និងការចំណាយជាក់លាក់លើការធ្វើជំរឿន និងការអង្កេតទ្រង់ទ្រាយធំ។ ក្នុងចន្លោះឆ្នាំ២០២១-២០២៥ វិទ្យាស្ថានជាតិស្ថិតិ មានចំណាយបន្ទុកបុគ្គលិកជាមធ្យមប្រមាណ ២ លានដុល្លារ ក្នុងមួយឆ្នាំ ខណៈចំណាយសម្រាប់ប្រតិបត្តិការទូទៅមានជាមធ្យមប្រមាណ ៦៧ ម៉ឺនដុល្លារក្នុងមួយឆ្នាំ។ ដោយឡែកចំណាយសម្រាប់ការងារជំរឿន និងអង្កេតធំៗ គឺជាប្រភេទចំណាយផលិតកម្មទិន្នន័យនិងស្ថិតិ ដោយផ្អែកទៅលើប្រតិទិននៃការងារជំរឿន និងអង្កេតដែលបានកំណត់ និងដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ក្នុងករណីមិនគិតបញ្ចូលចំណាយពីការងារជំរឿន និងអង្កេតធំៗ ចំណាយបន្ទុកបុគ្គលិកមានរហូតដល់ទៅ ៧៥% ធៀបនឹងចំណាយក្រៅបន្ទុកបុគ្គលិក មានប្រមាណត្រឹមតែ ២៥%។ សមាមាត្រនេះឆ្លុះបញ្ចាំងអំពីបន្ទុកធ្ងន់ធ្ងរនៃចំណាយបន្ទុកបុគ្គលិក ខណៈដែលស្ថាប័នទាំងមូលប្រឈមនឹងកង្វះខាតធនធាន និងសម្ភារបរិក្ខារចាំបាច់នានា សម្រាប់បម្រើឱ្យប្រតិបត្តិការប្រចាំថ្ងៃ។

### ២.៥.៤. សម្ភារបរិក្ខារ និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ

សម្ភារបរិក្ខារ និងហេដ្ឋារចនាសម្ព័ន្ធ មានសារៈសំខាន់ណាស់ក្នុងការធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃប្រតិបត្តិការ។ បច្ចុប្បន្ន ទីតាំងនៃវិទ្យាស្ថានជាតិស្ថិតិ ស្ថិតនៅក្នុងក្រសួងផែនការ ដោយមានអគារធ្វើការ និងទំហំការិយាល័យតូចចង្អៀត ដែលស្ថានភាពគ្រឿងបរិក្ខារការិយាល័យ និងបរិក្ខារគាំទ្រផ្សេងទៀត នៅមិនទាន់អាចឆ្លើយតបបានទៅនឹងតម្រូវការប្រើប្រាស់ ដើម្បីបំពេញមុខងារប្រតិបត្តិប្រចាំថ្ងៃឡើយ។

ទន្ទឹមនេះ សមត្ថភាពហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រង ចែករំលែក និងផ្សព្វផ្សាយទិន្នន័យស្ថិតិរបស់វិទ្យាស្ថានជាតិស្ថិតិនៅមានកម្រិត និងពុំទាន់បានធ្វើទំនើបកម្មគ្រប់គ្រាន់នៅឡើយ។ ជាក់ស្តែង ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលមានបច្ចុប្បន្ន គឺជាប្រព័ន្ធដែលត្រូវបានកសាងតាំងពីជំនាន់មុន និងមិនមានសមត្ថភាពគ្រប់គ្រាន់ឆ្លើយតបបានទៅនឹងការវិវត្តថ្មីៗ ដូចជា ទិន្នន័យធំ (big data) និងការធ្វើសមាហរណកម្មបញ្ចូលបញ្ញាសិប្បនិម្មិត (AI) ឬម៉ាស៊ីនស្វ័យសិក្សា (machine learning)។ ការពឹងផ្អែកលើប្រព័ន្ធមិនផ្លូវការ ដូចជាបណ្តាញតេឡេក្រាមក្នុងការចែករំលែកទិន្នន័យ ការប្រើប្រាស់គេហទំព័រច្រើនតែបែកខ្ញែកពីគ្នា សម្រាប់ការផ្សព្វផ្សាយស្ថិតិផ្លូវការ និងកង្វះធនធានមនុស្ស ដែលមានចំណេះដឹងផ្នែកបច្ចេកវិទ្យាព័ត៌មាននៅក្នុងការគ្រប់គ្រងប្រព័ន្ធ សុទ្ធតែជាបញ្ហាប្រឈម ដែលបន្សល់ទុកពីការអភិវឌ្ឍនាពេលមុន និងទាមទារឱ្យមានការពិនិត្យ រៀបចំឡើងវិញ។

## ២.៦. សមិទ្ធផលសំខាន់ៗ

ទោះបីជាមានបញ្ហាប្រឈមដូចបានរៀបរាប់ខាងលើ វិទ្យាស្ថានជាតិស្ថិតិបានសម្រេចនូវសមិទ្ធិផលជាច្រើនក្នុងការអភិវឌ្ឍប្រព័ន្ធស្ថិតិជាតិ និងវិទ្យាស្ថានជាតិស្ថិតិ ដែលសមិទ្ធផលទាំងនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការកសាងក្របខ័ណ្ឌដ៏រឹងមាំសម្រាប់ការប្រមូល វិភាគ និងផ្សព្វផ្សាយទិន្នន័យ ព្រមទាំងគាំទ្រដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់ប្រទេស ការធ្វើផែនការគោលនយោបាយ និងការចូលរួមជាមួយស្ថាប័នអន្តរជាតិ។ ក្នុងរយៈពេលកន្លងមក វិទ្យាស្ថានជាតិស្ថិតិ សម្រេចបានសមិទ្ធផលសំខាន់ៗ ក្នុងការផលិត និងផ្សព្វផ្សាយទិន្នន័យស្ថិតិសំខាន់ៗ ដូចជា៖

- **ជំរឿនប្រជាជន** (ឆ្នាំ១៩៦២ ១៩៩៨ ២០០៨ ២០១៩)
- **ជំរឿនកសិកម្ម** (ឆ្នាំ២០១៣ ២០២៣)
- **ជំរឿនសេដ្ឋកិច្ច** (ឆ្នាំ២០១១ ២០២២)
- **អង្កេតចន្លោះជំរឿនប្រជាជន** (ឆ្នាំ២០០៤ ២០១៣ ២០២៤)
- **អង្កេតចន្លោះជំរឿនសេដ្ឋកិច្ច** (ឆ្នាំ២០១៤ ២០១៩)
- **អង្កេតសេដ្ឋកិច្ច សង្គមកិច្ច** (ឆ្នាំ១៩៩៣/៩៤ ១៩៩៦ ១៩៩៧ ១៩៩៩ ២០០៤ ២០០៧-២០១៧ ២០១៩/២០ ២០២១/២២ ២០២៣ ២០២៥)
- **អង្កេតកសិកម្ម** (ឆ្នាំ២០១៩ ២០២៥)
- **អង្កេតកម្លាំងពលកម្ម** (ឆ្នាំ២០០០ ២០០១ ២០១២ ២០១៩ ២០២៥)
- **អង្កេតប្រជាសាស្រ្ត និងសុខភាព** (ឆ្នាំ២០០០ ២០០៥ ២០១០ ២០១៤ ២០២១/២២)
- **អង្កេតសហគ្រាស** (ឆ្នាំ១៩៩៩ ២០០៥)
- **ការចងក្រងទិន្នន័យគណនេយ្យជាតិ និងសន្ទស្សន៍ថ្លៃអ្នកប្រើប្រាស់**
- **ការចងក្រងទិន្នន័យស្ថិតិកម្ពុជាប្រចាំឆ្នាំ** ។ល។

## ២.៧. បញ្ហាប្រឈម

បើទោះបីជាមានសមិទ្ធផល និងវឌ្ឍនភាពជាច្រើន ក្នុងការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធស្ថិតិរបស់ប្រទេសក៏ដោយ ក៏វិទ្យាស្ថានជាតិស្ថិតិផ្ទាល់ជួបប្រទះនឹងបញ្ហាប្រឈមជាប្រព័ន្ធដែលប៉ះពាល់ដល់ប្រសិទ្ធភាពនៃការផលិត និងផ្សព្វផ្សាយទិន្នន័យ នៅក្នុងប្រព័ន្ធស្ថិតិជាតិជារួម ជាពិសេសការឈានទៅអភិវឌ្ឍវិទ្យាស្ថានជាតិស្ថិតិ ក្នុងកម្រិតថ្មីមួយទៀត។ បញ្ហាប្រឈមទាំងនេះ ជារឿយៗស្តែងចេញតាមរយៈ ភាពមានកម្រិតនៃគុណភាពទិន្នន័យស្ថិតិ, ភាពទាន់ពេលក្នុងការផលិត និងផ្សព្វផ្សាយ វិសាលភាព កម្រិតលម្អិត និងភាពជាប់លាប់នៃទិន្នន័យ, ភាពមិនពេញលេញ និងអសង្គតិភាពនៃសំណុំទិន្នន័យស្ថិតិ, ការពន្យារពេល ឬភាពយឺតយ៉ាវក្នុងការប្រមូល ផលិត និងផ្សព្វផ្សាយទិន្នន័យស្ថិតិ, គម្លាតក្នុងការអនុវត្តស្តង់ដា និងវិធីសាស្រ្តនៃការប្រមូល និងផលិតទិន្នន័យស្ថិតិ និងអសង្គតិភាពនៃនីតិវិធីរាយការណ៍ និងចែករំលែកទិន្នន័យ ជាដើម។

បញ្ហាប្រឈមទាំងនេះ គឺជាបញ្ហាប្រឈមផ្ទាល់របស់វិទ្យាស្ថានជាតិស្ថិតិផង ហើយក៏ជាបញ្ហារួមរបស់គ្រប់តួអង្គនៃប្រព័ន្ធស្ថិតិជារួមផងដែរ ជាពិសេសការយល់ដឹងជាសាធារណៈអំពីតម្រូវការ និងគុណតម្លៃនៃទិន្នន័យស្ថិតិ ។ បញ្ហាប្រឈមទាំងនេះ បណ្តាលមកពីកត្តាសំខាន់ៗ ដូចជា៖

(១). **យន្តការសម្របសម្រួល៖** ភាពមានកម្រិតនៃកិច្ចសហប្រតិបត្តិការរវាងវិទ្យាស្ថានជាតិស្ថិតិជាមួយបណ្តាក្រសួង ស្ថាប័ន និងតួអង្គពាក់ព័ន្ធ ជាពិសេសលើការចែករំលែកទិន្នន័យរដ្ឋបាល ការផលិតទិន្នន័យស្ថិតិ មានលក្ខណៈបែកខ្ញែក មិនទាន់មានសង្គតភាព និងពិបាកក្នុងការស្វែងរក។

(២). **ប្រព័ន្ធអភិបាលកិច្ច និងរំហូរការងារ៖** យន្តការស្ថាប័ន ដែលរួមបញ្ចូលទាំង កត្តាអភិបាលកិច្ច ការរៀបចំរចនាសម្ព័ន្ធស្ថាប័ន ការកំណត់មុខងារស្នូល និងការជំរុញអនុវត្តមុខងារនៅតាមបណ្តាអង្គភាពជំនាញក្រោមឱវាទ ជាដើម បានជះឥទ្ធិពលដល់ប្រសិទ្ធភាពនៃប្រតិបត្តិការ និងការធានាគុណភាពទិន្នន័យស្ថិតិ។

(៣). **កត្តាធនធានមនុស្ស៖** តម្រូវការក្នុងការពង្រឹងជំនាញដល់មន្ត្រី ឱ្យកាន់តែមានសមត្ថភាពខ្ពស់, ការរៀបចំ និងបែងចែកតួនាទីនិងភារកិច្ចឱ្យបានសមស្រប និងការពង្រឹងការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈ ដើម្បីបង្កើនសមត្ថភាពស្ថាប័ន ក្នុងការបំពេញតម្រូវការទិន្នន័យស្ថិតិដែលកាន់តែកើនឡើង និងទាមទារគុណភាពកាន់តែខ្ពស់ ។

(៤). **ទីកន្លែងធ្វើការ និងសម្ភារបរិក្ខារគាំទ្រ៖** បរិស្ថានសម្រាប់ការបំពេញការងារបច្ចុប្បន្ន នៅពុំទាន់អាចអនុញ្ញាតឱ្យមន្ត្រី ធ្វើការបានប្រកបដោយប្រសិទ្ធភាពខ្ពស់ ដោយបន្ទប់ធ្វើការមានលក្ខណៈតូចចង្អៀត ហើយសម្ភារបរិក្ខារគាំទ្រកិច្ចដំណើរការ នៅមានកម្រិត។

(៥). **ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា៖** កង្វះធនធាន និងក្របខ័ណ្ឌរួម សម្រាប់ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងថ្នាលទិន្នន័យរួម ដែលអាចធ្វើអន្តរប្រតិបត្តិការ និងសមាហរណកម្មទិន្នន័យ ព្រមទាំងការបន្តអភិវឌ្ឍប្រព័ន្ធដែលមានភាពបែកខ្ញែក បានបង្កជាបញ្ហាស្មុគស្មាញកាន់តែច្រើន ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យារបស់វិទ្យាស្ថានជាតិស្ថិតិ។

# ៣. ទិសដៅនៃការអភិវឌ្ឍស្ថាប័នវិទ្យាស្ថានជាតិស្ថិតិ

## ៣.១. ទស្សនាទានរួម

ទិសដៅនៃការអភិវឌ្ឍស្ថាប័នវិទ្យាស្ថានជាតិស្ថិតិ គឺដើម្បីកសាងស្ថាប័នស្ថិតិជាតិ ដែលបំពេញតួនាទីប្រកបដោយឧត្តមភាព និងឯករាជ្យភាពវិជ្ជាជីវៈ ក្នុងការផលិត និងផ្សព្វផ្សាយទិន្នន័យស្ថិតិប្រកប ដោយគុណភាពខ្ពស់ ភាពទាន់ពេល និងឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់កម្ពុជា។ ការអភិវឌ្ឍស្ថាប័ននេះ នឹងផ្តោតជាសំខាន់ទៅលើការធ្វើស្ថាប័ននីយកម្ម ជាពិសេស ការបង្កើនស្វ័យភាពដល់វិទ្យាស្ថានជាតិស្ថិតិ ការកសាងសមត្ថភាពស្ថាប័ន ការលើកកម្ពស់ស័ក្តិសិទ្ធភាពប្រតិបត្តិការ និងការធ្វើទំនើបកាវូបនីយកម្មហេដ្ឋារចនាសម្ព័ន្ធគាំទ្រ។

ដំណើរនៃការកែទម្រង់ និងពង្រឹងសមត្ថភាពនៃវិទ្យាស្ថានជាតិស្ថិតិ ត្រូវបានគិតគូរដោយឈរលើអភិក្រមជាដំណាក់កាលចំនួន ៣ ដែលដំណាក់កាលនីមួយៗផ្តោតលើការដោះស្រាយបញ្ហាជាក់លាក់ សំដៅដោះស្រាយជាអតិបរមានូវបញ្ហាជារចនាសម្ព័ន្ធ ខណៈធានាស្ថិរភាពប្រតិបត្តិការ និងចីរភាពស្ថាប័នរយៈពេលវែង។

**ដំណាក់កាលអន្តរកាលដំបូង៖** នៅដំណាក់កាលទី ១ នេះ រាជរដ្ឋាភិបាលធ្វើការកែទម្រង់ភ្លាមៗ ផ្តោតលើការដោះស្រាយជាបន្ទាន់ នូវបញ្ហាប្រឈមសំខាន់ៗ ដើម្បីធ្វើឱ្យប្រសើរឡើងក្នុងការអនុវត្តមុខងារស្នូល ដែលរួមបញ្ចូលទាំងការកែសម្រួលយន្តការស្ថាប័ន ប្រព័ន្ធអភិបាលកិច្ច រចនាសម្ព័ន្ធចាត់តាំង និងមុខងារមួយចំនួន ខណៈធានាឱ្យបាននូវស្ថិរភាពប្រតិបត្តិការ ព្រមទាំងការពង្រឹងឡើងវិញនូវយន្តការសម្របសម្រួល។

**ដំណាក់កាលជំរុញការអនុវត្ត៖** ដំណាក់កាលនេះផ្តោតលើការពង្រឹងសមត្ថភាពមន្ត្រី និងសមត្ថភាពស្ថាប័ន ក្នុងការផលិត និងផ្សព្វផ្សាយទិន្នន័យស្ថិតិមូលដ្ឋានសំខាន់ៗ ប្រកបដោយគុណភាព និងអនុលោមតាមស្តង់ដា និងក្រឹត្យក្រមទិន្នន័យជាអន្តរជាតិ។ ក្នុងដំណាក់កាលនេះ មនុស្សគឺជាស្នូលនៃការកែទម្រង់ ដោយរាជរដ្ឋាភិបាល នឹងជំរុញការរៀបចំធនធានមនុស្សនៃវិទ្យាស្ថានជាតិស្ថិតិឱ្យកាន់តែមានប្រសិទ្ធភាព តាមរយៈការពង្រាយមន្ត្រីគ្រប់កម្រិតទៅតាមជំនាញ និងបទពិសោធន៍ការងារ ការបំពាក់បំប៉នជំនាញស្នូលចាំបាច់ និងការកៀរគរធនធានមនុស្សដែលមានជំនាញខ្ពស់។

**ដំណាក់កាលប្រត្តិកម្ម៖** ដំណាក់កាលនេះ ផ្តោតលើការបន្តពង្រឹងសមត្ថភាពស្ថាប័នពង្រីកវិសាលភាព និងបន្តពង្រឹងគុណភាព នៃការផលិតទិន្នន័យស្ថិតិ។ ក្នុងដំណាក់កាលនេះ ការអភិវឌ្ឍស្ថាប័នវិទ្យាស្ថានជាតិស្ថិតិ មានគោលដៅពង្រីកវិសាលភាព និងសមត្ថភាពរបស់ស្ថាប័ន ដើម្បីឈានដល់ស្តង់ដាកាន់តែប្រសើរឡើង ទាំងក្នុងទិដ្ឋភាពនៃការចងក្រងផលិតទិន្នន័យស្ថិតិ និងទិដ្ឋភាពនៃប្រតិបត្តិការរបស់ស្ថាប័ន។

## ៣.២. កត្តាជំរុញ

បើទោះបីជា ក្របខ័ណ្ឌទស្សនាទាននៃការកែទម្រង់ និងពង្រឹងសមត្ថភាពវិទ្យាស្ថានជាតិស្ថិតិ ត្រូវបានគិតគូរជាប្រព័ន្ធ និងមានដំណើរវិវឌ្ឍជាបណ្តើរៗហើយក្តី កិច្ចការនេះទាមទារនូវពេលច្រើន ដើម្បីធានានូវប្រសិទ្ធភាពយូរអង្វែង ក្នុងគោលដៅកសាង និងផ្លាស់ប្តូរមុខមាត់ថ្មីជូនស្ថាប័ននេះឱ្យក្លាយជាស្ថាប័នប្រកបដោយឧត្តមភាព និងចីរភាព ក្នុងការបំពេញមុខងារ។ ចំណុចគន្លឹះដែលជាកត្តាជំរុញគន្លឹះ (key enablers) នាំទៅរកការផ្លាស់ប្តូរជាវិជ្ជមាននៃការកែទម្រង់នេះ គឺការពង្រឹងភាពជាអ្នកដឹកនាំនៃស្ថាប័ន ការកសាងធនធានមនុស្ស និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគាំទ្រ។

**ការពង្រឹងភាពជាអ្នកដឹកនាំ៖** ភាពជាអ្នកដឹកនាំ គឺជាកត្តាជំរុញ និងជាមូលដ្ឋាននៃភាពជោគជ័យរបស់ស្ថាប័ន។ អ្នកដឹកនាំត្រូវមានចក្ខុវិស័យវែងឆ្ងាយ ការគិតគូរជាយុទ្ធសាស្ត្រ និងសមត្ថភាពគ្រប់គ្រាន់ក្នុងការដឹកនាំ ចាត់ចែងកិច្ចដំណើរការស្ថាប័ន ទាំងបច្ចេកទេស រដ្ឋបាល និងហិរញ្ញវត្ថុ ។ ទន្ទឹមនេះ ការលើកកម្ពស់ប្រព័ន្ធអភិបាលកិច្ចស្ថាប័នមានសារៈសំខាន់ក្នុងការធានានូវសិទ្ធិអំណាចគ្រប់គ្រាន់ ដល់អ្នកដឹកនាំគ្រប់កម្រិត ស្របជាមួយនឹងការលើកកម្ពស់ គណនេយ្យភាព និងតម្លាភាពនៅក្នុងប្រព័ន្ធការងារ។

**ការកសាងធនធានមនុស្ស៖** ធនធានមនុស្ស ដែលមានចំណេះដឹង ជំនាញ និងក្រមសីលធម៌វិជ្ជាជីវៈខ្ពស់ គឺជាកត្តាជំរុញដ៏ចម្បងមួយ ដើម្បីអនុញ្ញាតឱ្យវិទ្យាស្ថានជាតិស្ថិតិ អាចត្រៀមខ្លួនរួចរាល់ ឈានទៅកសាងស្ថាប័នប្រកបដោយសមត្ថភាពពេញលេញ និងអាចបំពេញបាននូវតម្រូវការកាន់តែច្រើនឡើងនៃទិន្នន័យស្ថិតិ។ អភិក្រម 5R នឹងត្រូវយកជាវិធានគោលក្នុងការគ្រប់គ្រង និងចាត់ចែងធនធានមនុស្សនៃវិទ្យាស្ថានជាតិស្ថិតិ រួមមាន (១). Retain ថែរក្សាមន្ត្រី (២). Retrain and retain បណ្តុះបណ្តាល និងថែរក្សាមន្ត្រី (៣). Reassign ពង្រាយមន្ត្រីឡើងវិញ (៤). Retrench កាត់បន្ថយមន្ត្រី និង (៥). Recruit ជ្រើសរើសមន្ត្រីថ្មី។

**ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគាំទ្រ៖** ការធ្វើទំនើបភាវូបនីយកម្មទីកន្លែងធ្វើការ និងប្រព័ន្ធការងារ តាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តគាំទ្រ ដូចជា សម្ភារបរិក្ខារទំនើប ថ្នាលឌីជីថល និងប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្រិតខ្ពស់ គឺជាកត្តាជំរុញមួយទៀត ដែលអនុញ្ញាតឱ្យវិទ្យាស្ថានជាតិស្ថិតិបំពេញប្រតិបត្តិការប្រកបដោយស័ក្តិសិទ្ធភាព។ ឌីជីថលូបនីយកម្មនៃប្រព័ន្ធការងារ នឹងចូលរួមធានាបាននូវដំណើរការផលិត និងផ្សព្វផ្សាយទិន្នន័យប្រកបដោយប្រសិទ្ធភាព និងលើកកម្ពស់កិច្ចប្រតិបត្តិការអន្តរក្រសួង-ស្ថាប័ន ។

# ៤. ផែនការអភិវឌ្ឍន៍ស្ថាប័ន

## ៤.១. ចក្ខុវិស័យ

វិទ្យាស្ថានជាតិស្ថិតិ មានចក្ខុវិស័យក្នុងការវិវត្តខ្លួនទៅជាស្ថាប័នទំនើប និងមានសមត្ថភាពខ្ពស់ក្នុងការផលិត និងចែករំលែកទិន្នន័យស្ថិតិប្រកបដោយគុណភាព គណនេយ្យភាព និងតម្លាភាព សំដៅលើកកម្ពស់ប្រព័ន្ធស្ថិតិជាតិ ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ។

## ៤.២. បេសកកម្ម

វិទ្យាស្ថានជាតិស្ថិតិ មានបេសកកម្ម ក្នុងការប្រមូល ការចងក្រង ការកែច្នៃ ការវិភាគ និងការផ្សព្វផ្សាយទិន្នន័យស្ថិតិប្រកបដោយគុណភាព ភាពជឿជាក់ ទាន់ពេល និងនិរន្តរភាព ដើម្បីគាំទ្រដល់ការរៀបចំគោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ក៏ដូចជាឆ្លើយតបទៅនឹងសេចក្តីត្រូវការទិន្នន័យស្ថិតិរបស់សាធារណជន វិស័យឯកជន សហគមន៍ជាតិ និងអន្តរជាតិ។

## ៤.៣. គុណតម្លៃស្ថាប័ន

វិទ្យាស្ថានជាតិស្ថិតិ កសាងស្ថាប័នមានសមត្ថភាពពេញលេញ និងបំពេញការងារក្នុងជវភាពនៃប្រព័ន្ធតួអង្គតែមួយ ដោយប្រកាន់យកគុណតម្លៃចំនួន៥ ។ **ស្ថាប័នមានសមត្ថភាពពេញលេញ** សំដៅលើស្ថាប័នដែលបំពេញការងារជាប្រព័ន្ធ មានជំនាញវិជ្ជាជីវៈខ្ពស់ ភាពសកម្ម និងបុរេសកម្ម ភាពស្អាតស្អំ និងសុចរិតភាព ក្នុងការបំពេញមុខងារ និងភារកិច្ចដែលច្បាប់ និងរាជរដ្ឋាភិបាលប្រគល់ឱ្យឱ្យសម្រេចបានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពខ្ពស់ និងក្នុងស្មារតីទទួលខុសត្រូវ។ **ជវភាពនៃប្រព័ន្ធតួអង្គតែមួយ** សំដៅលើការសហការបំពេញការងារជាមួយគ្នា នៅក្នុងប្រព័ន្ធការងារតែមួយ ដើម្បីឈានទៅសម្រេចបេសកកម្មរួម ដោយខិតខំបំពេញតួនាទីរៀងៗខ្លួន ព្រមទាំងមានការសហការជិតស្និទ្ធទាំងផ្ទៃក្នុង និងផ្ទៃក្រៅ ការសម្របសម្រួល ការយកចិត្តទុកដាក់ ការផ្តល់ព័ត៌មាន ការបំពេញឱ្យគ្នាទៅវិញទៅមក និងប្រកបដោយវិជ្ជាជីវៈ។ វិទ្យាស្ថានជាតិស្ថិតិ នឹងរក្សាឱ្យបាននូវគុណតម្លៃស្ថាប័នចំនួន ៥ ដូចខាងក្រោម៖

- **គុណភាព៖** ប្តេជ្ញាផលិត និងផ្សព្វផ្សាយទិន្នន័យស្ថិតិផ្លូវការ ប្រកបដោយភាពត្រឹមត្រូវគ្រប់ជ្រុងជ្រោយ និងទាន់ពេល ស្របតាមស្តង់ដាអន្តរជាតិ និងដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការប្រើប្រាស់។
- **ភាពជាអ្នកដឹកនាំ៖** ដើរតួនាទីជាអង្គភាពឈានមុខ ក្នុងការដឹកនាំសម្របសម្រួលប្រព័ន្ធស្ថិតិជាតិប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ព្រមទាំងជំរុញការកែទម្រង់ និងលើកកម្ពស់សមត្ថភាពផ្ទៃក្នុងស្ថាប័នជាប្រចាំ។

- **គណនេយ្យភាព៖** មានការទទួលខុសត្រូវខ្ពស់ ដោយផ្ដោតលើលទ្ធផល និងមានតម្លាភាពនូវរាល់សកម្មភាពនៃកិច្ចប្រតិបត្តិការ ជាពិសេសក្នុងការបំពេញមុខងារ និងភារកិច្ច ការគ្រប់គ្រង និងការប្រើប្រាស់ធនធាន។
- **សីលធម៌វិជ្ជាជីវៈ៖** ធ្វើប្រតិបត្តិការដោយប្រកាន់ខ្ជាប់នូវគោលការណ៍ស្វ័យភាព សុចរិតភាព ឯករាជ្យភាពវិជ្ជាជីវៈ និងការរក្សាការសម្ងាត់ ដើម្បីធានាបាននូវការទុកចិត្តពីអ្នកផ្ដល់ និងអ្នកប្រើប្រាស់ទិន្នន័យ។
- **នវានុវត្តន៍៖** ដឹកនាំ និងជំរុញការអភិវឌ្ឍឌីជីថលក្នុងវិស័យស្ថិតិ សំដៅលើកកម្ពស់សមត្ថភាពស្ថាប័ន និងប្រព័ន្ធស្ថិតិជាតិ ដើម្បីអាចសម្របខ្លួន និងចាប់យកអត្ថប្រយោជន៍ជាអតិបរមាពីបរិវត្តកម្មឌីជីថល។

**រូបភាពទី៤៖** គំនូសបំព្រួញផែនការអភិវឌ្ឍន៍ស្ថាប័នវិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០២៦-២០២៨



## ៤.៤. គោលដៅជាយុទ្ធសាស្ត្រ

ដោយផ្អែកលើចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃស្ថាប័នខាងលើ ផែនការអភិវឌ្ឍន៍ស្ថាប័ន វិទ្យាស្ថានជាតិស្ថិតិ ផ្តោតលើគោលដៅជាយុទ្ធសាស្ត្រ ចំនួន៥ ដូចខាងក្រោម៖

### ៤.៤.១. ការពង្រឹងយន្តការស្ថាប័ន និងការសម្របសម្រួលប្រព័ន្ធស្ថិតិជាតិ

លទ្ធផលចម្បងនៃគោលដៅយុទ្ធសាស្ត្រនេះ គឺការបង្កើននូវស្វ័យភាពរបស់វិទ្យាស្ថានជាតិស្ថិតិ ក្នុងការបំពេញមុខងារជាតួអង្គស្នូលក្នុងការសម្របសម្រួលប្រព័ន្ធស្ថិតិជាតិប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ គោលដៅយុទ្ធសាស្ត្រនេះរួមបញ្ចូលទិសដៅអាទិភាពសំខាន់ៗ ដូចខាងក្រោម៖

- **ការលើកកម្ពស់អភិបាលកិច្ចផ្ទៃក្នុង៖** រចនាសម្ព័ន្ធអភិបាលកិច្ច និងនីតិវិធីផ្ទៃក្នុងត្រូវបាន រៀបចំ និងអនុវត្តយ៉ាងម៉ត់ចត់ ដែលផ្តល់ជាការតម្រង់ទិសជាយុទ្ធសាស្ត្រ ធានាបាននូវ ស័ក្តិសិទ្ធភាពប្រតិបត្តិការ តម្លាភាពក្នុងការគ្រប់គ្រងធនធាន និងគណនេយ្យភាពក្នុងការ សម្រេចចិត្ត ដើម្បីសម្រេចបាននូវស្វ័យភាពកាន់តែប្រសើរ។
- **ពង្រឹងយន្តការសម្របសម្រួលប្រព័ន្ធស្ថិតិជាតិ៖** ជំរុញការធ្វើសមាហរណកម្ម និងសម្រប សម្រួលប្រព័ន្ធស្ថិតិជាតិទាំងមូល ដោយកំណត់តួនាទីភារកិច្ច និងស្តង់ដាច្បាស់លាស់ ដើម្បីលើកកម្ពស់គុណភាព ក្នុងការប្រមូលនិងផលិតទិន្នន័យស្ថិតិ។ លិខិតបទដ្ឋានគាំទ្រ នានា នឹងត្រូវបានដាក់ឱ្យប្រើប្រាស់ ដើម្បីឱ្យមានការចែករំលែកទិន្នន័យរវាងស្ថាប័ន ប្រកបដោយសុវត្ថិភាព និងធានានូវការការពារឯកជនភាពទិន្នន័យ។
- **ជំរុញភាពជាដៃគូជាមួយគ្រប់ភាគីពាក់ព័ន្ធ៖** ជំរុញកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ ទាំងស្ថាប័នរដ្ឋ ដៃគូអភិវឌ្ឍ និងវិស័យឯកជន ក្នុងការផលិត និងផ្សព្វផ្សាយទិន្នន័យ ស្ថិតិ។ រាល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីខាងក្រៅ នឹងត្រូវសម្របសម្រួលរួម ឱ្យស្របតាមផែនការអាទិភាពជាតិ ដែលធ្វើឱ្យការប្រើប្រាស់ជំនួយកាន់តែមានប្រសិទ្ធភាព និងមាននិរន្តរភាពខ្ពស់។

### ៤.៤.២. ការពង្រឹងការអនុវត្តមុខងារស្នូល និងការធានាគុណភាពទិន្នន័យស្ថិតិ

លទ្ធផលចម្បងនៃគោលដៅយុទ្ធសាស្ត្រនេះ គឺការផលិតទិន្នន័យស្ថិតិ ដែលមានគុណភាពខ្ពស់ ទាន់ពេល ផ្អែកលើតម្រូវការ និងមានសារៈសំខាន់ដល់ការរៀបចំគោលនយោបាយជាតិ ព្រមទាំងស្រប តាមស្តង់ដាអន្តរជាតិ។ គោលដៅយុទ្ធសាស្ត្រនេះរួមបញ្ចូលទិសដៅអាទិភាពសំខាន់ៗ ដូចខាងក្រោម៖

- **ការពង្រឹងការអនុវត្តតួនាទីភារកិច្ច៖** រចនាសម្ព័ន្ធស្ថាប័នត្រូវបានរៀបចំឡើងវិញប្រកប ដោយប្រសិទ្ធភាពខ្ពស់ ស្របតាមឧត្តមានុវត្តជាអន្តរជាតិ ដោយមានការកំណត់តួនាទី និងភារកិច្ចច្បាស់លាស់។ ការអនុវត្តស្តង់ដានីតិវិធីជាក់លាក់ក្នុងការធ្វើប្រតិបត្តិការ នឹងធ្វើ ឱ្យរាល់ដំណើរការការងារទាំងអស់មានសង្គតិភាព និងបំពេញឱ្យគ្នា ព្រមទាំងមានយន្តការ ប្រតិគុណ្យការផ្ទៃក្នុង។

- **ការធានាគុណភាពទិន្នន័យ៖** ទិន្នន័យស្ថិតិផ្លូវការទាំងអស់ត្រូវបានធានាគុណភាពស្រប តាមស្តង់ដាអន្តរជាតិ តាមរយៈការអនុវត្តក្របខ័ណ្ឌស្តង់ដាជាក់លាក់ដែលបង្កើតបាននូវភាពជឿទុកចិត្តខ្ពស់ពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីគាំទ្រដល់ការធ្វើសេចក្តីសម្រេចចិត្តនានារបស់រាជរដ្ឋាភិបាល។
- **ការយកចិត្តទុកដាក់លើការផ្សព្វផ្សាយ៖** វិទ្យាស្ថានជាតិស្ថិតិផ្តល់ភាពងាយស្រួលចូលប្រើប្រាស់ និងភាពបើកទូលាយនៃទិន្នន័យស្ថិតិផ្លូវការ តាមរយៈមធ្យោបាយផ្សព្វផ្សាយថ្មីៗ និងឧបករណ៍ឌីជីថល។ វិទ្យាស្ថានជាតិស្ថិតិ បង្កើតឱ្យមានយន្តការទទួលមតិកែលម្អជាប្រចាំ ដើម្បីធានាថាផលិតផលទិន្នន័យស្ថិតិរបស់ខ្លួន មានភាពពាក់ព័ន្ធ និងមានតម្លៃបន្ថែមខ្ពស់សម្រាប់អ្នកប្រើប្រាស់។

### ៤.៤.៣. ការអភិវឌ្ឍធនធានមនុស្ស

លទ្ធផលចម្បងនៃគោលដៅយុទ្ធសាស្រ្តនេះ គឺការកសាងបាននូវធនធានមនុស្ស ដែលមានសមត្ថភាពខ្ពស់ មានភាពជាអ្នកដឹកនាំ និងឆន្ទៈមុតស្រួច ដែលអាចចូលរួមធានានិរន្តរភាព និងភាពជោគជ័យនៃបេសកកម្មរបស់វិទ្យាស្ថានជាតិស្ថិតិ។ គោលដៅយុទ្ធសាស្រ្តនេះរួមបញ្ចូលទិសដៅអាទិភាពសំខាន់ៗ ដូចខាងក្រោម៖

- **ការលើកកម្ពស់ភាពជាអ្នកដឹកនាំ៖** វិទ្យាស្ថានជាតិស្ថិតិ ជាថ្នាលបណ្តុះភាពជាអ្នកដឹកនាំក្នុងវិស័យស្ថិតិប្រកបដោយសមត្ថភាពខ្ពស់នៅគ្រប់កម្រិតនៃស្ថាប័ន និងមានផែនការធានាដល់និរន្តរភាពនៃមុខងារសំខាន់ៗ។
- **ការគ្រប់គ្រងធនធានមនុស្ស៖** វិទ្យាស្ថានជាតិស្ថិតិ មានគោលដៅកសាងស្ថាប័នឱ្យក្លាយជាបណ្តុំនៃធនធានមនុស្សដែលមានសមត្ថភាពខ្ពស់ ក្នុងការផលិត និងវិភាគទិន្នន័យស្ថិតិ។ វិទ្យាស្ថានជាតិស្ថិតិ នឹងរៀបចំក្របខ័ណ្ឌសមត្ថភាពក្នុងវិស័យស្ថិតិ សម្រាប់ជាមូលដ្ឋានវាយតម្លៃ គ្រប់គ្រង ចាត់ចែង និងកសាងសមត្ថភាពធនធានមនុស្សប្រកបដោយប្រសិទ្ធភាព ដើម្បីរក្សា និងទាក់ទាញអ្នកជំនាញបច្ចេកទេសបន្ថែម។
- **ការបណ្តុះបណ្តាលជំនាញ៖** មន្ត្រីនៃវិទ្យាស្ថានជាតិស្ថិតិទាំងអស់ ត្រូវមានជំនាញស្ថិតិយ៉ាងហោចត្រឹមកម្រិតមូលដ្ឋាន និងបន្តអភិវឌ្ឍឈានទៅរកជំនាញបច្ចេកទេសខ្ពស់។ ការបណ្តុះបណ្តាលផ្ទៃក្នុង គឺជាគន្លឹះក្នុងការធានាបានមន្ត្រីគ្រប់រូប មានចំណេះដឹង និងសមត្ថភាពគ្រប់គ្រាន់ ក្នុងការឈានទៅសម្រេចបេសកកម្មរួម។

### ៤.៤.៤. ការរៀបចំទីកន្លែងធ្វើការសមរម្យ និងវប្បធម៌ការងារវិជ្ជមាន

លទ្ធផលចម្បងនៃគោលដៅយុទ្ធសាស្រ្តនេះ គឺការបង្កើតឱ្យមានបរិយាកាស និងប្រព័ន្ធការងារប្រកបដោយផលិតភាពខ្ពស់ ភាពជាម្ចាស់ការ និងការទទួលខុសត្រូវដល់មន្ត្រីទាំងអស់ ដែលជំរុញឱ្យមន្ត្រីគ្រប់ៗរូបសម្រេចបាននូវលទ្ធផលការងារជាអតិបរមា ខណៈរក្សាបានតុល្យភាពជីវិតឯកជន និងការងារ។ គោលដៅយុទ្ធសាស្រ្តនេះរួមបញ្ចូលទិសដៅអាទិភាពសំខាន់ៗ ដូចខាងក្រោម៖

- **ការកែលម្អបរិស្ថានការងារ៖** ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបរិក្ខារគាំទ្រនានា ត្រូវបានធ្វើទំនើបកម្មពេញលេញ និងមានលក្ខណៈសមរម្យ ដើម្បីបង្កើតជាកន្លែងធ្វើការទំនើប និងសហថាមវន្តក្នុងការបំពេញភារកិច្ច។ ទីកន្លែងធ្វើការថ្មី និងទំនើប នឹងផ្តល់នូវបរិយាកាសអំណោយផលដល់ការបំពេញការងារប្រកបដោយនវានុវត្តន៍ និងប្រសិទ្ធភាព។
- **ការលើកកម្ពស់វប្បធម៌ការងារវិជ្ជមាន:** វប្បធម៌ការងារដែលផ្អែកលើ ក្រមប្រតិបត្តិវិជ្ជាជីវៈ និងគណនេយ្យភាពបុគ្គល ត្រូវបានបង្កើតឡើងយ៉ាងរឹងមាំ។ ការរៀបចំនូវយន្តការជានាគណនេយ្យភាព នឹងរួមចំណែកដល់ការលើកកម្ពស់សីលធម៌ ការទទួលខុសត្រូវ និងភាពជាម្ចាស់ការរបស់មន្ត្រីគ្រប់កម្រិត ក្នុងការសម្រេចគោលដៅស្ថាប័ន។
- **ការរៀបចំយន្តការលើកទឹកចិត្តសមស្រប៖** យន្តការលើកទឹកចិត្តដែល ផ្អែកលើសមិទ្ធកម្ម ត្រូវដាក់ឱ្យដំណើរការ ដែលធានាថាមន្ត្រីដែលមានកិច្ចខិតខំប្រឹងប្រែង និងសម្រេចបានស្នាដៃ ត្រូវបានផ្តល់ការលើកទឹកចិត្ត និងមានទទួលស្គាល់ជាសាធារណៈ។

### ៤.៤.៥. ការកសាងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់ជ្រុងជ្រោយ

លទ្ធផលចម្បងនៃគោលដៅយុទ្ធសាស្ត្រនេះ គឺការធ្វើបរិវត្តកម្មឌីជីថលពេញលេញ នៃប្រព័ន្ធការងារ និងដំណើរការផលិតកម្មទិន្នន័យស្ថិតិរបស់វិទ្យាស្ថានជាតិស្ថិតិដែលផ្តល់នូវភាពទាន់ពេលភាពពាក់ព័ន្ធ និងសុវត្ថិភាពទិន្នន័យ តាមរយៈប្រព័ន្ធអេកូឡូស៊ីទិន្នន័យជាតិទំនើប។ គោលដៅយុទ្ធសាស្ត្រនេះរួមបញ្ចូលទិសដៅអាទិភាពសំខាន់ៗ ដូចខាងក្រោម៖

- **ប្រព័ន្ធឌីជីថលសម្រាប់ការគ្រប់គ្រងទិន្នន័យ៖** វិទ្យាស្ថានជាតិស្ថិតិ នឹងដាក់ចេញនូវក្របខ័ណ្ឌនិម្មាបនកម្មហេដ្ឋារចនាសម្ព័ន្ធឌីជីថលរបស់ខ្លួន ដើម្បីជាផែនទីបង្ហាញផ្លូវសម្រាប់រយៈពេលមធ្យម។ ជាមួយគ្នានេះ វិទ្យាស្ថានជាតិស្ថិតិមានគោលដៅកសាងនូវថ្នាលទិន្នន័យរួមដែលអាចគ្រប់គ្រង និងធ្វើសមាហរណកម្មទិន្នន័យពីគ្រប់ប្រភពក្នុងប្រព័ន្ធស្ថិតិជាតិប្រកបដោយប្រសិទ្ធភាព។
- **ការធ្វើឌីជីថលូបនីយកម្មរំហូរការងារ៖** ប្រតិបត្តិការទូទៅរបស់វិទ្យាស្ថានជាតិស្ថិតិ ត្រូវបានធ្វើឌីជីថលូបនីយកម្មជាបណ្តើរៗ ដើម្បីលើកកម្ពស់ស័ក្តិសិទ្ធភាពស្ថាប័ន ពង្រឹងយន្តការត្រួតពិនិត្យផ្ទៃក្នុង ធានាថាការចែករំលែកទិន្នន័យ និងព័ត៌មានបានទាន់ពេល។ ការណ៍នេះធ្វើឱ្យការចូលប្រើប្រាស់ និងវិភាគទិន្នន័យមានភាពងាយស្រួល និងរហ័ស។
- **ការធានាសន្តិសុខទិន្នន័យ៖** សន្តិសុខទិន្នន័យ ភាពសម្ងាត់ និងភាពឯកជន ត្រូវបានធានាក្នុងកម្រិតខ្ពស់បំផុត ដោយអនុលោមតាមស្តង់ដាអន្តរជាតិ។ វិទ្យាស្ថានជាតិស្ថិតិនឹងរៀបចំយុទ្ធសាស្ត្រសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត ដែលមានភាពរឹងមាំ និងផ្តល់នូវនិរន្តរភាព នៃប្រតិបត្តិការទិន្នន័យ និងការពារទំនុកចិត្តសាធារណជន។

## ៤.៥. ផែនការសកម្មភាពគន្លឹះ

ផែនការសកម្មភាពគន្លឹះ នៃផែនការអភិវឌ្ឍន៍ស្ថាប័នវិទ្យាស្ថានជាតិស្ថិតិ ត្រូវបានរៀបចំសម្រាប់រយៈពេល ៣ឆ្នាំ ចាប់ពីឆ្នាំ២០២៦ ដល់ឆ្នាំ២០២៨ ដែលរួមបញ្ចូលនូវ **សកម្មភាពគន្លឹះសរុបចំនួន ៧៩** (ដូចមានលម្អិតក្នុងតារាងឧបសម្ព័ន្ធ) ដោយបែងចែកទៅតាមគោលដៅជាយុទ្ធសាស្ត្រទាំង ៥ រួមមាន៖

- **គោលដៅជាយុទ្ធសាស្ត្រទី១៖** ការពង្រឹងយន្តការស្ថាប័ន និងការសម្របសម្រួលប្រព័ន្ធស្ថិតិជាតិ មាន ១៧ សកម្មភាពគន្លឹះ
- **គោលដៅជាយុទ្ធសាស្ត្រទី២៖** ការពង្រឹងការអនុវត្តមុខងារស្នូល និងការធានាគុណភាពទិន្នន័យស្ថិតិ មាន ១៨ សកម្មភាពគន្លឹះ
- **គោលដៅជាយុទ្ធសាស្ត្រទី៣៖** ការអភិវឌ្ឍធនធានមនុស្ស មាន ១៦ សកម្មភាព
- **គោលដៅជាយុទ្ធសាស្ត្រទី៤៖** ការរៀបចំទីកន្លែងធ្វើការសមរម្យ និងវប្បធម៌ការងារវិជ្ជមាន មាន ១៥ សកម្មភាពគន្លឹះ និង
- **គោលដៅជាយុទ្ធសាស្ត្រទី៥៖** ការកសាងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់ជ្រុងជ្រោយ មាន ១៣ សកម្មភាពគន្លឹះ ។

សកម្មភាពគន្លឹះមួយចំនួន គឺជាកិច្ចការដែលត្រូវអនុវត្តជាប្រចាំ ខណៈសកម្មភាពគន្លឹះមួយចំនួនទៀត គឺជាកិច្ចការត្រូវសម្រេចឱ្យបានក្នុងក្របខ័ណ្ឌពេលវេលាជាក់លាក់ ។ ដូច្នេះ ជាការអនុវត្តសកម្មភាពគន្លឹះតាមឆ្នាំ រួមមាន៖ ឆ្នាំ២០២៦ មានសកម្មភាពគន្លឹះចំនួន ៤៥, ឆ្នាំ២០២៧ មានសកម្មភាពគន្លឹះចំនួន៥៩ និងឆ្នាំ២០២៨ មានសកម្មភាពគន្លឹះចំនួន៥២ ។

# ៥. ការអនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

## ៥.១. យន្តការអនុវត្ត

ដើម្បីអនុវត្តបានជោគជ័យនូវផែនការអភិវឌ្ឍន៍ស្ថាប័នវិទ្យាស្ថានជាតិស្ថិតិ ទាមទារឱ្យមានការកំណត់ឱ្យបានច្បាស់លាស់នូវយន្តការអនុវត្តប្រកបដោយស្មារតីបុរេសកម្ម កិច្ចសហការ និងការទទួលខុសត្រូវខ្ពស់។ **នាយកវិទ្យាស្ថានជាតិស្ថិតិ** មានតួនាទីដឹកនាំការអនុវត្តផែនការអភិវឌ្ឍន៍ស្ថាប័នជារួម ជាពិសេសការសម្រេចឱ្យបាននូវផែនការសកម្មភាពគន្លឹះ រយៈពេល ៣ឆ្នាំ ដែលបានដាក់ចេញ ។ **ប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានជាតិស្ថិតិ** មានតួនាទីដឹកនាំការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្ត លទ្ធផលសម្រេចបាន និងការតម្រង់ទិសសម្រាប់កិច្ចការបន្ត។

### ៥.១.១. តួអង្គពាក់ព័ន្ធ និងតួនាទីភារកិច្ច

ការអនុវត្តផែនការអភិវឌ្ឍន៍ស្ថាប័ននេះ មានតួអង្គពាក់ព័ន្ធសំខាន់ៗចំនួន៤៖

– **ក្រុមប្រឹក្សាស្ថិតិ** ជាយន្តការកម្រិតនយោបាយ ដែលមានតួនាទីតម្រង់ទិសលើការរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការងារស្ថិតិ ការរៀបចំគោលនយោបាយស្ថិតិផ្លូវការ និងយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ ការកំណត់មុខសញ្ញា និងតម្រូវការស្ថិតិផ្លូវការ ការកំណត់កាលបរិច្ឆេទនៃការធ្វើជំរឿន និងអង្កេត និងការកំណត់ទិសដៅយុទ្ធសាស្ត្រ និងអាទិភាពការងារសម្រាប់វិទ្យាស្ថានជាតិស្ថិតិ ដែលជាស្ថាប័នស្នូលក្នុងប្រព័ន្ធស្ថិតិជាតិ។

– **គណៈកម្មាធិការសម្របសម្រួលស្ថិតិ** ជាយន្តការបច្ចេកទេស អន្តរស្ថាប័ន ដើម្បីជំរុញការធ្វើសមាហរណកម្មប្រព័ន្ធស្ថិតិជាតិ តាមរយៈការសម្របសម្រួល និងសហប្រតិបត្តិការ រវាងវិទ្យាស្ថានជាតិស្ថិតិ ក្រសួង-ស្ថាប័ន និងអង្គភាពស្ថិតិដែលបានចាត់តាំង។

– **ក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានជាតិស្ថិតិ** មានតួនាទីផ្តល់ការត្រួតពិនិត្យ និងអភិបាលកិច្ចជាយុទ្ធសាស្ត្រ លើការអនុវត្តផែនការអភិវឌ្ឍន៍ស្ថាប័ន។ ក្រុមប្រឹក្សាភិបាល ពិនិត្យ និងអនុម័តលើទិសដៅការងារសំខាន់ៗ និងការបែងចែកធនធាន ព្រមទាំងចូលរួមធានានូវគណនេយ្យភាព និងប្រសិទ្ធភាពនៃការអនុវត្តផែនការអភិវឌ្ឍន៍ស្ថាប័ន ដោយធ្វើការត្រួតពិនិត្យវឌ្ឍនភាពជាប្រចាំ ដាក់ចេញនូវវិធានការដោះស្រាយបញ្ហាប្រឈមនានា និងកែសម្រួលផែនការការងារ តាមការចាំបាច់។

– **អង្គភាពប្រតិបត្តិនៃវិទ្យាស្ថានជាតិស្ថិតិ** ដែលមាននាយកវិទ្យាស្ថានជាតិស្ថិតិជាប្រធាន គឺជាតួអង្គស្នូលនៃការអនុវត្តផែនការអភិវឌ្ឍន៍ស្ថាប័ន។ វិទ្យាស្ថានជាតិស្ថិតិ នឹងបង្កើតនូវក្រុមការងារកែទម្រង់ដែលមានតួនាទី ជួយដល់ប្រធានស្ថាប័ន ក្នុងការអនុវត្តផែនការអភិវឌ្ឍន៍ស្ថាប័ន និងចូលរួម តាមដាន និងបូកសរុបវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពគន្លឹះ។

### ៥.១.២. ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំដើម្បីជំរុញ និងធានាបាននូវប្រសិទ្ធភាពនៃការអនុវត្ត។ យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃនេះ ស្ថិតក្រោមការដឹកនាំដោយក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានជាតិស្ថិតិ ដែលមានភារកិច្ចតាមដាន និងត្រួតពិនិត្យនូវរាល់វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពគន្លឹះ ផ្តល់ការណែនាំតម្រង់ទិសជាយុទ្ធសាស្ត្រ និងដាក់ចេញនូវវិធានការអាទិភាពបន្ថែម តាមការចាំបាច់។ ក្របខ័ណ្ឌនេះ រួមបញ្ចូលនូវយន្តការដូចខាងក្រោម៖

(១). **ការរៀបចំផែនការតាមដាន និងត្រួតពិនិត្យ៖** នាយកវិទ្យាស្ថានជាតិស្ថិតិ ដោយមាននាយកដ្ឋាន និងក្រុមការងារជំនាញជាសេនាធិការ ត្រូវរៀបចំផែនការតាមដាន និងត្រួតពិនិត្យ ដែលរួមបញ្ចូលនូវសកម្មភាព សូចនាករសមិទ្ធកម្មគន្លឹះ និងក្របខ័ណ្ឌពេលវេលាជាក់លាក់ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត។

(២). **របបប្រជុំតាមដាន និងត្រួតពិនិត្យ៖** បន្ទាប់ពីផែនការតាមដាន និងត្រួតពិនិត្យ ត្រូវបានអនុម័ត, ក្រុមប្រឹក្សាភិបាលត្រូវរៀបចំកិច្ចប្រជុំរៀងរាល់ ៣ខែម្តង ដើម្បីតាមដានវឌ្ឍនភាព សមិទ្ធកម្ម និងបញ្ហាប្រឈមនៃការអនុវត្ត។

(៣). **ការរៀបចំរបាយការណ៍វឌ្ឍនភាព៖** ដោយផ្អែកលើផែនការតាមដាន និងត្រួតពិនិត្យដែលបានអនុម័ត នាយកវិទ្យាស្ថានជាតិស្ថិតិ ត្រូវរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តការងារ បញ្ហាប្រឈម និង/ឬសំណើដំណោះស្រាយ ជារៀងរាល់ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ ផ្តល់យោបល់ និងជាកម្មវត្ថុសម្រាប់កិច្ចប្រជុំក្រុមប្រឹក្សាភិបាល។

(៤). **ការវាយតម្លៃ៖** ការវាយតម្លៃអំពីលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍ស្ថាប័ន ត្រូវធ្វើឡើងដោយក្រុមការងារចម្រុះ ក្រោមការដឹកនាំតម្រង់ទិសរបស់ក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានជាតិស្ថិតិ។ របាយការណ៍វាយតម្លៃបិទបញ្ចប់ការអនុវត្តនឹងត្រូវដាក់ជូនក្រុមប្រឹក្សាភិបាល ដើម្បីជាមូលដ្ឋានសម្រាប់ការដាក់ចេញទិសដៅការងារបន្តទៀត ក្នុងការអភិវឌ្ឍស្ថាប័ន។

### ៥.២. ធនធានគាំទ្រ

ដើម្បីធានាការអនុវត្តប្រកបដោយជោគជ័យនៃផែនការអភិវឌ្ឍន៍ស្ថាប័ន សម្រាប់វិទ្យាស្ថានជាតិស្ថិតិ ចាំបាច់ត្រូវរៀបចំយន្តការហិរញ្ញវត្ថុគាំទ្រសមស្រប និងមាននិរន្តរភាព។ ប្រភពធនធានគាំទ្រដើម្បីអនុវត្តផែនការអភិវឌ្ឍន៍ស្ថាប័ន វិទ្យាស្ថានជាតិស្ថិតិ រួមមាន៖

– **ការវិភាជពីថវិការដ្ឋ៖** វិទ្យាស្ថានជាតិស្ថិតិ មានថវិកាប្រចាំឆ្នាំដែលជាការវិភាជពីថវិការដ្ឋសម្រាប់ចំណាយលើបៀវត្ស ប្រតិបត្តិការទូទៅ និងការអនុវត្តការងារស្ថិតិសំខាន់ៗ រួមមានជំរឿន អង្កេត និងការងារស្ថិតិផ្សេងៗទៀត ស្របទិសដៅការងារ ដូចមានកំណត់ក្នុងច្បាប់ស្តីពីស្ថិតិ និងក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធ។

– **ការកៀរគរជំនួយបច្ចេកទេស និងហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍ៖** ការរៀបចំឱ្យមានយន្តការរួមមួយសម្រាប់កៀរគរជំនួយបច្ចេកទេស និងហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍ និងភាគីពាក់ព័ន្ធ នឹងក្លាយជាឧបករណ៍ដ៏សំខាន់ ដើម្បីបំពេញតម្រូវការវិនិយោគលើការអភិវឌ្ឍធនធានមនុស្ស ការធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រសំខាន់ៗ។

– **ប្រភពចំណូលដោយវិទ្យាស្ថានជាតិស្ថិតិផ្ទាល់៖** ក្នុងរយៈពេលមធ្យម និងវែង វិទ្យាស្ថានជាតិស្ថិតិអាចទទួលបាននូវប្រភពចំណូលផ្ទាល់បន្ថែម តាមរយៈការផ្តល់សេវាកម្មស្ថិតិ រួមមានការប្រមូលទិន្នន័យ ការវិភាគ និងការសិក្សាស្រាវជ្រាវ ជាដើម។

## ៥.៣. ហានិភ័យនៃការអនុវត្ត

ហានិភ័យសំខាន់ៗមួយចំនួន អាចរារាំង ឬពន្យារពេលដល់ការអនុវត្តផែនការអភិវឌ្ឍន៍ស្ថាប័នវិទ្យាស្ថានជាតិស្ថិតិ រួមមាន៖

– **សមត្ថភាពមន្ត្រី៖** វិទ្យាស្ថានជាតិស្ថិតិមានមន្ត្រីច្រើន ប៉ុន្តែប្រឈមនឹងបញ្ហាភាពមានកម្រិតលើផ្នែកសមត្ថភាពជំនាញ ជាពិសេសក្នុងការអនុវត្តវិធីសាស្ត្រស្ថិតិស៊ីជម្រៅ។ កត្តានេះគឺជាហានិភ័យមួយ ដែលមន្ត្រីមួយចំនួនអាចប្រឈមនឹងការលំបាក ក្នុងការចាប់យកជំនាញបច្ចេកទេសកម្រិតខ្ពស់ ឱ្យស្របតាមតម្រូវការរបស់ស្ថាប័នដែលកំពុងវិវឌ្ឍខ្លួន និងអាចបន្ទច់បង្អាក់ដល់ការធ្វើទំនើបភាវូបនីយកម្ម និងបង្កផលលំបាកដល់ស័ក្តិសិទ្ធភាពស្ថាប័ន។ ការពង្រឹង ការគ្រប់គ្រង ចាត់ចែងធនធានមនុស្ស និងជំរុញការបណ្តុះបណ្តាល កសាងសមត្ថភាពនឹងដើរតួនាទីចម្បង ក្នុងការកាត់បន្ថយហានិភ័យនេះ។

– **ការទទួលយកការផ្លាស់ប្តូរ៖** ការកែទម្រង់ស្ថាប័នតម្រូវឱ្យមានការកែសម្រួល រំហូរការងារ តួនាទី ភារកិច្ច និងនិយាមប្រតិបត្តិផ្សេងទៀត ដែលអាចជាបញ្ហាប្រឈមសម្រាប់មន្ត្រីក្នុងការសម្របខ្លួន។ ដូច្នេះ ការទទួលយកការផ្លាស់ប្តូរមិនបានពេញលេញ និងគ្រប់គ្រាន់ អាចបន្ទច់បង្អាក់ដំណើរការកែទម្រង់ និងគោលដៅនៃផែនការអភិវឌ្ឍន៍ស្ថាប័ន។ ក្នុងន័យនេះ ចាំបាច់ត្រូវមានការគិតគូរឱ្យបានគត់មត់ លើការធានាបាននូវអត្ថប្រយោជន៍រយៈពេលវែងសម្រាប់មន្ត្រីគ្រប់រូប ទន្ទឹមនឹងការជំរុញការយល់ដឹងរួមគ្នា លើទិសដៅនៃការកែទម្រង់ និងបេសកកម្មរួមរបស់ស្ថាប័ន។

– **កិច្ចសហការអន្តរស្ថាប័ន៖** ទិន្នន័យស្ថិតិគ្រប់ជ្រុងជ្រោយ និងអាចទុកចិត្តបាន ពឹងផ្អែកលើកិច្ចសហការខ្ពស់របស់ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ។ ការធានាបាននូវយន្តការសម្របសម្រួល និងកិច្ចសហការលើការចែករំលែកទិន្នន័យប្រកបដោយប្រសិទ្ធភាព មានភាពចាំបាច់ក្នុងការផលិតទិន្នន័យស្ថិតិដែលមានភាពបំពេញឱ្យគ្នា និងអាចឆ្លើយតបបាននឹងតម្រូវការរបស់អ្នកប្រើប្រាស់។

– **ហានិភ័យផ្នែកហិរញ្ញវត្ថុ៖** ធនធានហិរញ្ញវត្ថុសមស្រប គឺជាកត្តាចាំបាច់ សម្រាប់គាំទ្រដល់ប្រតិបត្តិការនៃវិទ្យាស្ថានជាតិស្ថិតិ ការធ្វើជំរឿន និងអង្កេត ការកសាងមូលធនមនុស្ស និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធគាំទ្រ។ ភាពមានកម្រិតនៃធនធានហិរញ្ញវត្ថុ អាចបង្កហានិភ័យដល់ភាពជោគជ័យនៃផែនការអភិវឌ្ឍន៍ស្ថាប័ន។ ដូច្នេះ ដើម្បីកាត់បន្ថយហានិភ័យនេះ ផែនការថវិកាប្រចាំឆ្នាំ ចាំបាច់ត្រូវរៀបចំប្រកបដោយភាពជាម្ចាស់ មានការគិតគូរគ្រប់ជ្រុងជ្រោយ និងទាមទារឱ្យមានការគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធ។

# ៦. សេចក្តីសន្និដ្ឋាន

វិទ្យាស្ថានជាតិស្ថិតិ ជាតួអង្គស្នូលនៃប្រព័ន្ធស្ថិតិកម្ពុជា ដែលមានមុខងារចម្បងក្នុងការដឹកនាំ សម្របសម្រួល លើការកសាងប្រព័ន្ធស្ថិតិសមាហរណកម្មមួយ ដែលបំពេញទៅដល់តម្រូវការនៃទិន្នន័យស្ថិតិ សម្រាប់ជាមូលដ្ឋានក្នុងការដាក់ចេញទិសដៅគោលនយោបាយ ការសម្រេចចិត្ត និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធី និង/ឬគោលនយោបាយអភិវឌ្ឍន៍ជាតិ។ បន្ទាប់ពីការវិវត្តខ្លួនអស់ជាច្រើនទសវត្សរ៍ វិទ្យាស្ថានជាតិស្ថិតិបានឈានដល់ដំណាក់កាលសំខាន់មួយ ដែលតម្រូវឱ្យមានការធ្វើទំនើបភាវូបនីយកម្មបន្ថែម តាមរយៈការដាក់ចេញនូវផែនការអភិវឌ្ឍន៍ស្ថាប័ន ដែលមានភាពគត់មត់គ្រប់ជ្រុងជ្រោយ និងដោះស្រាយបាននូវបញ្ហាប្រឈមនានា ។

**ផែនការអភិវឌ្ឍន៍ស្ថាប័ន វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០២៦-២០២៨** ត្រូវបានរៀបចំឡើង ដើម្បីដាក់ចេញនូវក្របខ័ណ្ឌរួមមួយ ក្នុងការពង្រឹងយន្តការស្ថាប័ន និងការសម្របសម្រួលប្រព័ន្ធស្ថិតិជាតិ លើកកម្ពស់ការអនុវត្តមុខងារ និងធានាគុណភាពទិន្នន័យ អភិវឌ្ឍន៍ធនធានមនុស្ស រៀបចំទីកន្លែងធ្វើការសមរម្យ និងវប្បធម៌ការងារវិជ្ជមាន និងកសាងហេដ្ឋារចនាសម្ព័ន្ធឌីជីថលរបស់វិទ្យាស្ថានជាតិស្ថិតិ។ ផែនការអភិវឌ្ឍន៍ស្ថាប័នវិទ្យាស្ថានជាតិស្ថិតិ ដាក់ចេញនូវ**ផែនការសកម្មភាពគន្លឹះ សរុបចំនួន ៧៩** ដោយចេញជា ៥ផ្នែក សម្រាប់រយៈពេល ៣ឆ្នាំ ក្នុងនោះ ឆ្នាំ២០២៦ មាន ចំនួន ៤៥ សកម្មភាព, ឆ្នាំ២០២៧ មានចំនួន ៥៩ សកម្មភានិងឆ្នាំ២០២៨ មាន ចំនួន ៥២ សកម្មភាព។ ដើម្បីគាំទ្រដល់ការអនុវត្តផែនការនេះសម្រេចបានដោយជោគជ័យ ការរៀបចំយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃឱ្យបានគត់មត់ ដែលត្រួតពិនិត្យដោយផ្ទាល់ពីក្រុមប្រឹក្សាភិបាល និងការជំរុញបន្ថែមដោយនាយកវិទ្យាស្ថានជាតិស្ថិតិ ជាពិសេសក្រុមការងារកែទម្រង់ស្ថិតិ នឹងធានាបាននូវគណនេយ្យភាព សមិទ្ធកម្ម និងអនុញ្ញាតឱ្យមានភាពបត់បែនទាន់ពេលវេលាស្របតាមតម្រូវការចាំបាច់។

ភាពជោគជ័យនៃផែនការអភិវឌ្ឍន៍ស្ថាប័នវិទ្យាស្ថានជាតិស្ថិតិ គឺអាស្រ័យលើការចូលរួមយ៉ាងសកម្ម និងបុរេសកម្មពីភាគីពាក់ព័ន្ធទាំងអស់ ពោលគឺថ្នាក់ដឹកនាំ មន្ត្រីរាជការ និងក្រសួង ស្ថាប័នដែលជាដៃគូរបស់វិទ្យាស្ថានជាតិស្ថិតិ។ ផែនការអភិវឌ្ឍន៍ស្ថាប័ននេះ មានចរិតជាការកែទម្រង់ស្ថាប័ន ដើម្បីពង្រឹងស័ក្តិសិទ្ធភាពប្រតិបត្តិការ ប្រសិទ្ធភាពការងារ និងបង្កើតបរិយាកាសការងារអំណោយផលដល់ថ្នាក់ដឹកនាំ និងមន្ត្រីស្ថិតិគ្រប់ជាន់ថ្នាក់។ ទោះជាយ៉ាងនេះក្តី ដូចគ្នានឹងការកែទម្រង់ផ្សេងទៀត ការផ្លាស់ប្តូរទាមទារនូវការអត់ធ្មត់ និងការសម្របខ្លួន ដើម្បីសម្រេចបាននូវគុណប្រយោជន៍រួម សម្រាប់ការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា។

# ឧបសម្ព័ន្ធ៖ ផែនការសកម្មភាពគន្លឹះ

| ល.រៀង | ល.រ. | ផែនការសកម្មភាពគន្លឹះ | ក្របខ័ណ្ឌពេលវេលា | | |
|---|---|---|---|---|---|
| | | | ២០២៦ | ២០២៧ | ២០២៨ |
| គោលដៅជាយុទ្ធសាស្ត្រទី១៖ ការពង្រឹងយន្តការស្ថាប័ន និងការសម្របសម្រួលប្រព័ន្ធស្ថិតិជាតិ | | | | | |
| ១.១. ការលើកកម្ពស់យន្តការអភិបាលកិច្ចផ្ទៃក្នុង | | | | | |
| ១ | ១ | ពង្រឹងយន្តការអភិបាលកិច្ច និងការតម្រង់ទិសរបស់ក្រុមប្រឹក្សាភិបាល ដោយរៀបចំកិច្ចប្រជុំជាប្រចាំ និងដាក់ចេញនូវរបៀបវារៈ និងទិសដៅការងារជាយុទ្ធសាស្ត្រ | ✓ | ✓ | ✓ |
| ២ | ២ | ពិនិត្យ និងអនុម័តវិធានផ្ទៃក្នុងចាំបាច់នានា សម្រាប់ការអនុវត្តកិច្ចប្រតិបត្តិការជាគ្រឹះស្ថានសាធារណៈរដ្ឋបាល | ✓ | | |
| ៣ | ៣ | រៀបចំបង្កើតក្រុមការងារពិសេស ទទួលបន្ទុកជំរុញការកែទម្រង់ និងអភិវឌ្ឍសមត្ថភាពស្ថាប័នវិទ្យាស្ថានជាតិស្ថិតិ | ✓ | | |
| ៤ | ៤ | រៀបចំយន្តការធានាប្រតិតុល្យការក្នុងការគ្រប់គ្រង និងការបំពេញការងារ ដែលដឹកនាំដោយក្រុមប្រឹក្សាភិបាល | ✓ | ✓ | ✓ |
| ៥ | ៥ | ដឹកនាំការវាយតម្លៃឯករាជ្យ (Independent Review) លើដំណើរការស្ថាប័ន រៀងរាល់ ៣ ឆ្នាំម្តង | | | ✓ |
| ១.២. ការជំរុញយន្តការសម្របសម្រួលប្រព័ន្ធស្ថិតិជាតិ | | | | | |
| ៦ | ១ | ចូលរួមពង្រឹងយន្តការក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិ តាមរយៈការសម្របសម្រួលឱ្យមានកិច្ចប្រជុំទៀងទាត់ កំណត់របៀបវារៈជាយុទ្ធសាស្ត្រ និងរបបរាយការណ៍ច្បាស់លាស់ | ✓ | ✓ | ✓ |
| ៧ | ២ | ពិនិត្យឡើងវិញអនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការនៃប្រព័ន្ធស្ថិតិជាតិ | ✓ | | |
| ៨ | ៣ | ពិនិត្យឡើងវិញអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង | ✓ | | |
| ៩ | ៤ | សិក្សាវាយតម្លៃ និងរៀបចំឡើងវិញនូវយន្តការសម្របសម្រួលជាមួយនឹងក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការចែករំលែកទិន្នន័យ និងធ្វើសមាហរណកម្មទិន្នន័យ | | ✓ | |

| | | | | | |
|---|---|---|---|---|---|
| ១០ | ៥ | រៀបចំការចុះអនុស្សារណៈនៃការយោគយល់គ្នា ជាមួយក្រសួង-ស្ថាប័ននីមួយៗ ក្នុងការចែករំលែកទិន្នន័យ ដោយកំណត់នូវស្តង់ដា សម្រាប់ការរាយការណ៍ និងម៉េតាទិន្នន័យច្បាស់លាស់ | | ✓ | ✓ |
| ១១ | ៦ | រៀបចំគោលការណ៍ណែនាំរួម សម្រាប់ការអនុវត្តអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង ឱ្យមានប្រសិទ្ធភាព | | ✓ | |
| ១២ | ៧ | ពិនិត្យសិក្សាក្នុងការរៀបចំបទប្បញ្ញត្តិគតិយុត្តចាំបាច់បន្ថែម ដើម្បីពង្រឹងតួនាទីរបស់វិទ្យាស្ថានជាតិស្ថិតិ ក្នុងការសម្របសម្រួលរបស់ប្រព័ន្ធស្ថិតិជាតិ | | | ✓ |
| **១.៣. ការលើកកម្ពស់ភាពជាដៃគូ** | | | | | |
| ១៣ | ១ | បង្កើតយន្តការសម្របសម្រួលរួម សម្រាប់រាល់កិច្ចសហប្រតិបត្តិការអន្តរជាតិ ការទទួលការគាំទ្រជាហិរញ្ញប្បទាន និងជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍ និង/ឬការអនុវត្តភាពជាដៃគូផ្សេងទៀត ជាមួយភាគីខាងក្រៅ | ✓ | | |
| ១៤ | ២ | ជំរុញការរៀបចំកិច្ចសហប្រតិបត្តិការ ឬភាពជាដៃគូផ្លូវការ ជាមួយស្ថាប័នស្ថិតិនៃប្រទេសអន្តរជាតិ | | ✓ | ✓ |
| ១៥ | ៣ | រៀបចំបង្កើតកម្មវិធីស្រាវជ្រាវថ្មីៗ ដោយសហការជាមួយស្ថាប័នជាដៃគូក្នុង និងក្រៅប្រទេស ដើម្បីចែករំលែកចំណេះដឹង និងពង្រឹងសមត្ថភាពមន្ត្រីលើប្រធានបទជាក់លាក់ | ✓ | ✓ | ✓ |
| ១៦ | ៤ | ពង្រីកកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នស្រាវជ្រាវ និងសាកលវិទ្យាល័យក្នុងស្រុក ដើម្បីជំរុញការប្រើប្រាស់ទិន្នន័យស្ថិតិ និងការបណ្តុះបណ្តាល | ✓ | ✓ | ✓ |
| ១៧ | ៥ | រៀបចំព្រឹត្តិការណ៍ "វេទិកាស្ថិតិជាតិប្រចាំឆ្នាំ" ដើម្បីលើកកម្ពស់ភាពជាដៃគូជាមួយគ្រប់ភាគីពាក់ព័ន្ធ និងទទួលយកមតិយោបល់សម្រាប់តម្រង់ទិសសកម្មភាពការងារស្ថិតិឱ្យស្របនឹងតម្រូវការរបស់អ្នកប្រើប្រាស់ | ✓ | ✓ | ✓ |
| **គោលដៅជាយុទ្ធសាស្ត្រទី២៖ ការពង្រឹងការអនុវត្តមុខងារស្នូល និងធានាគុណភាពទិន្នន័យស្ថិតិ** | | | | | |
| **២.១. ការពង្រឹងការបែងចែក និងអនុវត្តតួនាទីភារកិច្ច** | | | | | |
| ១៨ | ១ | រៀបចំការវាយតម្លៃស័ក្តិសិទ្ធភាពនៃប្រតិបត្តិការ និងវំហូរការងាររបស់នាយកដ្ឋាននីមួយៗ ដើម្បីស្វែងយល់អំពីបញ្ហាប្រឈម និងកត្តារាំងស្ទះសំខាន់ៗ | ✓ | | |
| ១៩ | ២ | រៀបចំគោលការណ៍ណែនាំរួម សម្រាប់ការលើកកម្ពស់ស័ក្តិសិទ្ធភាពប្រតិបត្តិការ និងវំហូរការងារនៃវិទ្យាស្ថានជាតិស្ថិតិ | | ✓ | |
| ២០ | ៣ | បង្កើតយន្តការតាមដាន និងត្រួតពិនិត្យជាប្រចាំ លើស័ក្តិសិទ្ធភាពនៃវំហូរការងាររបស់នាយកដ្ឋាននីមួយៗ | | ✓ | ✓ |

| | | | | | |
|---|---|---|---|---|---|
| ២១ | ៤ | រៀបចំស្តង់ដានីតិវិធីប្រតិបត្តិ សម្រាប់ដំណើរការផលិតទិន្នន័យស្ថិតិផ្លូវការសំខាន់ៗ | | | ✓ |
| ២២ | ៥ | រៀបចំឱ្យមានផែនការសកម្មភាពប្រចាំឆ្នាំ និងសូចនាករសមិទ្ធកម្មគន្លឹះ សម្រាប់នាយកដ្ឋាននីមួយៗ ក្នុងការអនុវត្តការងារ | ✓ | ✓ | ✓ |
| ២៣ | ៦ | ពង្រឹងយន្តការត្រួតពិនិត្យផ្ទៃក្នុង (Internal Audit) ដើម្បីធានាអនុលោមភាពតាមនីតិវិធីប្រតិបត្តិ និងបទប្បញ្ញត្តិជាធរមាន | ✓ | ✓ | ✓ |
| **២.២. ការធានាគុណភាពទិន្នន័យស្ថិតិ** | | | | | |
| ២៤ | ១ | ជំរុញការអនុវត្តនូវរាល់អនុសាសន៍ដែលបានដាក់ចេញនៅក្នុង របាយការណ៍សង្កេតការណ៍ស្តីពីស្តង់ដា និងក្រឹត្យក្រមនៃទិន្នន័យស្ថិតិ (Data ROSC) ដោយមូលនិធិរូបិយវត្ថុអន្តរជាតិ | ✓ | ✓ | ✓ |
| ២៥ | ២ | ត្រួតពិនិត្យឡើងវិញលើវិធីសាស្ត្រនៃការផលិតទិន្នន័យស្ថិតិសំខាន់ៗរបស់វិទ្យាស្ថានជាតិស្ថិតិ ដើម្បីធ្វើបច្ចុប្បន្នភាព និងកែលម្អស្របតាមស្តង់ដាអន្តរជាតិ | ✓ | ✓ | |
| ២៦ | ៣ | រៀបចំ និងដាក់ឱ្យប្រើប្រាស់ "សៀវភៅគុណភាពទិន្នន័យ" (Data Quality Handbook) ដែលផ្តល់នូវនិយាមសំខាន់ៗក្នុងការធានាគុណភាពទិន្នន័យស្ថិតិផ្លូវការ | | | ✓ |
| ២៧ | ៤ | រៀបចំបង្កើតយន្តការបច្ចេកទេស "ក្រុមប្រឹក្សាគុណភាពទិន្នន័យ" (Data Quality Board) ដើម្បីត្រួតពិនិត្យ ធ្វើសុពលភាព និងផ្តល់យោបល់លើរាល់ទិន្នន័យស្ថិតិ និងរបាយការណ៍ស្ថិតិសំខាន់ៗ | | ✓ | |
| ២៨ | ៥ | អនុវត្តការធ្វើសវនកម្មគុណភាពទិន្នន័យ (Data Quality Audit) លើស្ថិតិផ្លូវការសំខាន់ៗរៀងរាល់ ២ ឆ្នាំម្តង | | | ✓ |
| **២.៣. ការផ្សព្វផ្សាយទិន្នន័យស្ថិតិ** | | | | | |
| ២៩ | ១ | ដាក់ចេញនូវប្រតិទិនផ្សព្វផ្សាយទិន្នន័យស្ថិតិ (Data Release Calendar) ប្រចាំឆ្នាំ ឆមាស និងត្រីមាស និងរៀបចំយន្តការតាមដានការអនុវត្តឱ្យមានប្រសិទ្ធភាព | ✓ | ✓ | ✓ |
| ៣០ | ២ | រៀបចំយន្តការក្នុងការលើកកម្ពស់ទំនាក់ទំនងសាធារណៈ ដោយកំណត់នូវនីតិវិធីប្រតិបត្តិជាក់លាក់ ក្នុងការបកស្រាយស្ថិតិផ្លូវការ និងការឆ្លើយតបនូវសំណួរនានា | | ✓ | ✓ |
| ៣១ | ៣ | សិក្សាស្ថានភាពតម្រូវការទិន្នន័យស្ថិតិ និងភាពពេញចិត្តរបស់អ្នកប្រើប្រាស់ លើប្រសិទ្ធភាពនៃការផ្សព្វផ្សាយ និងលទ្ធភាពទទួលបានទិន្នន័យស្ថិតិផ្លូវការ | | ✓ | ✓ |
| ៣២ | ៤ | បន្តជំរុញការកែលម្អផ្ទាំងបង្ហាញនៃគេហទំព័រផ្លូវការ របស់វិទ្យាស្ថានជាតិស្ថិតិ | ✓ | ✓ | ✓ |

| | | | | | |
|---|---|---|---|---|---|
| ៣៣ | ៥ | ជំរុញការផ្សព្វផ្សាយទិន្នន័យស្ថិតិ ក្នុងទម្រង់សាមញ្ញ និងប្រកបដោយភាពច្នៃប្រឌិត តាមរយៈប្រព័ន្ធទំនាក់ទំនងសង្គមផ្លូវការរបស់វិទ្យាស្ថានជាតិស្ថិតិ | ✓ | ✓ | ✓ |
| ៣៤ | ៦ | ផ្សព្វផ្សាយជាសាធារណៈនូវរបាយការណ៍វាយតម្លៃគុណភាពស្ថិតិ (Quality Assessment Reports) សម្រាប់ស្ថិតិផ្លូវការសំខាន់ៗ | | | ✓ |
| ៣៥ | ៧ | រៀបចំ "សេចក្ដីសង្ខេបគោលនយោបាយ" (Policy Briefs) តាមប្រធានបទស្ថិតិសំខាន់ៗ សម្រាប់ការផ្សព្វផ្សាយជាសាធារណៈ | | ✓ | ✓ |
| **គោលដៅជាយុទ្ធសាស្ត្រទី៣៖ ការអភិវឌ្ឍធនធានមនុស្ស** | | | | | |
| **៣.១. ការលើកកម្ពស់ភាពជាអ្នកដឹកនាំ** | | | | | |
| ៣៦ | ១ | ដាក់ចេញនូវក្របខ័ណ្ឌសមត្ថភាពសម្រាប់ភាពជាអ្នកដឹកនាំ នៃស្ថាប័នវិទ្យាស្ថានជាតិស្ថិតិ | ✓ | | |
| ៣៧ | ២ | រៀបចំកម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំ ទៅតាមគោលដៅនៃក្របខ័ណ្ឌសមត្ថភាព សម្រាប់អ្នកដឹកនាំដែលមានភាពលេចធ្លោ (emerging leaders) អ្នកដឹកនាំកម្រិតកណ្ដាល (mid-level leaders) និងអ្នកដឹកនាំថ្នាក់ប្រតិបត្តិ (executive leaders) | ✓ | ✓ | ✓ |
| ៣៨ | ៣ | ផ្ដល់ការបណ្ដុះបណ្ដាលរយៈពេលខ្លីលើជំនាញដឹកនាំ និងគ្រប់គ្រង សម្រាប់មន្ត្រី ក្រោយពេលទទួលបានការតែងតាំងក្នុងមុខងារគ្រប់គ្រង ឬដឹកនាំអង្គភាព | ✓ | ✓ | ✓ |
| **៣.២. ការគ្រប់គ្រងធនធានមនុស្ស** | | | | | |
| ៣៩ | ១ | រៀបចំក្របខ័ណ្ឌសមត្ថភាព (competency framework) សម្រាប់មន្ត្រីស្ថិតិទូទៅ នៃវិទ្យាស្ថានជាតិស្ថិតិ ដើម្បីជាមូលដ្ឋានក្នុងការគ្រប់គ្រង និងចាត់ចែងធនធានមនុស្ស | ✓ | | |
| ៤០ | ២ | សិក្សា និងកំណត់តម្រូវការមន្ត្រីនៅតាមអង្គភាពនីមួយៗ និងដាក់ចេញនូវផែនការជ្រើសរើស ដោយផ្អែកលើក្របខ័ណ្ឌសមត្ថភាពដែលបានដាក់ចេញ | ✓ | | |
| ៤១ | ៣ | រៀបចំកម្មវិធីហាត់ការ (Internship Program) ដោយសហការជាមួយគ្រឹះស្ថានឧត្តមសិក្សា ក្នុងស្រុក ដើម្បីទាក់ទាញធនធានមនុស្សមានសក្ដានុពល | ✓ | ✓ | ✓ |
| ៤២ | ៤ | ពិនិត្យលទ្ធភាពព្រាយមន្ត្រីឡើងវិញ ទៅតាមបទពិសោធន៍ ស្នាដៃ សមត្ថភាព និងគុណវុឌ្ឍិ | ✓ | | |
| ៤៣ | ៥ | រៀបចំ និងដាក់ឱ្យអនុវត្តក្របខ័ណ្ឌវិជ្ជាជីវៈក្នុងវិស័យស្ថិតិ ដែលអនុញ្ញាតឱ្យមន្ត្រីអាចឡើងតំណែងក្នុងនាមជាមន្ត្រីបច្ចេកទេសជាមន្ត្រីស្ថិតិវ័យក្មេង (junior statistician) មន្ត្រីស្ថិតិ (statistician) និងមន្ត្រីស្ថិតិជាន់ខ្ពស់ (senior statistician) | | ✓ | ✓ |

| | | | | | |
|---|---|---|---|---|---|
| ៤៤ | ៦ | ដាក់ចេញនូវលក្ខន្តិកៈដាក់លាក់ សម្រាប់ការដំឡើងឋានៈ និងតួនាទី ដោយផ្អែកលើសូចនាករសមិទ្ធកម្ម កិច្ចខិតខំប្រឹងប្រែង និងស្នាដៃ | | ✓ | ✓ |
| ៤៥ | ៧ | ដាក់ឱ្យដំណើរការប្រព័ន្ធវាយតម្លៃសមិទ្ធកម្មការងារ (Performance Evaluation) ដោយ រួមបញ្ចូលនូវក្របខ័ណ្ឌសមត្ថភាព និងសូចនាករសមិទ្ធកម្មគន្លឹះប្រចាំឆ្នាំ | ✓ | ✓ | ✓ |
| **៣.៣. ការបណ្តុះបណ្តាលជំនាញ** | | | | | |
| ៤៦ | ១ | រៀបចំការវាយតម្លៃសមត្ថភាពមន្ត្រីឡើងវិញ នៅគ្រប់កម្រិត ដោយផ្អែកលើក្របខ័ណ្ឌសមត្ថភាពដែលបានដាក់ចេញ | ✓ | | |
| ៤៧ | ២ | រៀបចំផែនការអភិវឌ្ឍន៍ជំនាញរយៈពេលមធ្យម សម្រាប់មន្ត្រីនៃវិទ្យាស្ថានជាតិស្ថិតិ ដោយធ្វើការបណ្តុះបណ្តាលជាដំណាក់កាល និងផ្អែកទៅតាមវិសាលភាពការងារជាក់ស្តែង | ✓ | | |
| ៤៨ | ៣ | សហការជាមួយដៃគូទាំងក្នុង និងក្រៅប្រទេស ដើម្បីកៀរគរការគាំទ្រលើការបណ្តុះបណ្តាលសមត្ថភាពរយៈពេលមធ្យម និងវែង | ✓ | ✓ | ✓ |
| ៤៩ | ៤ | សិក្សាលទ្ធភាពក្នុងការរៀបចំ «មជ្ឈមណ្ឌលបណ្តុះបណ្តាល និងអភិវឌ្ឍជំនាញ» មួយ ដែលស្ថិតក្រោមរចនាសម្ព័ន្ធរបស់វិទ្យាស្ថានជាតិស្ថិតិ ដើម្បីផ្តល់វគ្គបណ្តុះបណ្តាលផ្ទៃក្នុងជាប្រចាំ | | ✓ | |
| ៥០ | ៥ | ជំរុញការចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេស ទាំងថ្នាក់តំបន់ និងសកល ដោយមានការចាត់ចែងសមស្រប | ✓ | ✓ | ✓ |
| ៥១ | ៦ | ជំរុញការប្រើប្រាស់កម្មវិធីបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ (E-Learning Modules) សម្រាប់ជំនាញបច្ចេកទេសមូលដ្ឋាន | ✓ | ✓ | ✓ |
| **គោលដៅយុទ្ធសាស្ត្រទី៤៖ ការរៀបចំទីកន្លែងធ្វើការសមរម្យ និងវប្បធម៌ការងារវិជ្ជមាន** | | | | | |
| **៤.១. ការកែលម្អបរិស្ថានការងារ** | | | | | |
| ៥២ | ១ | ពន្លឿនការសាងសង់អគារថ្មី នៃវិទ្យាស្ថានជាតិស្ថិតិ | ✓ | ✓ | |
| ៥៣ | ២ | រៀបចំផែនការបំពាក់សម្ភារបរិក្ខារគាំទ្រ ជាដំណាក់កាល នៅតាមនាយកដ្ឋាន និងអង្គភាពនីមួយៗ | | ✓ | ✓ |
| ៥៤ | ៣ | ពង្រឹងការគ្រប់គ្រងបញ្ជីសារពើពន្ធទ្រព្យសម្បត្តិរដ្ឋ ដោយមានការកត់ត្រាច្បាស់លាស់ នូវ ទ្រព្យសម្បត្តិ ស្ថានភាព និងអាយុកាលជាដើម ស្របតាមបទដ្ឋានគតិយុត្តជាធរមាន | | ✓ | ✓ |
| ៥៥ | ៤ | ធ្វើការត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំ លើយន្តការនៃការបែងចែក និងប្រសិទ្ធភាពនៃការប្រើប្រាស់សម្ភារបរិក្ខារសំខាន់ៗ នៅតាមនាយកដ្ឋាន និងអង្គភាពនីមួយៗ | | ✓ | ✓ |

| | | | | | |
|---|---|---|---|---|---|
| ៥៦ | ៥ | រៀបចំឱ្យមានបណ្ណាល័យសាធារណៈ ដែលអនុញ្ញាតឱ្យមានការសិក្សាស្រាវជ្រាវ និងទទួលបាន ឯកសារស្ថិតិ និងរបាយការណ៍បោះពុម្ពនានា | | ✓ | |
| ៥៧ | ៦ | រៀបចំ និងដាក់ឱ្យអនុវត្តស្តង់ដាសុវត្ថិភាព និងអនាម័យនៅកន្លែងការងារ | | ✓ | ✓ |
| **៤.២. ការលើកកម្ពស់វប្បធម៌ការងារវិជ្ជមាន** | | | | | |
| ៥៦ | ១ | រៀបចំក្រមប្រតិបត្តិវិជ្ជាជីវៈ សម្រាប់មន្ត្រីនៃវិទ្យាស្ថានជាតិស្ថិតិ | ✓ | | |
| ៥៩ | ២ | ជំរុញសកម្មភាពនៃការបញ្ជ្រាបក្រមប្រតិបត្តិវិជ្ជាជីវៈ និងគុណតម្លៃស្នូលរបស់ស្ថាប័នដល់មន្ត្រីគ្រប់រូប | ✓ | ✓ | ✓ |
| ៦០ | ៣ | រៀបចំយន្តការផ្ទៃក្នុង សម្រាប់គ្រប់គ្រងជម្លោះ ការដោះស្រាយវិវាទ និងពាក្យបណ្តឹង ប្រកបដោយតម្លាភាព | ✓ | | |
| ៦១ | ៤ | ដាក់ឱ្យអនុវត្តយន្តការវាយតម្លៃទៅវិញទៅមកប្រចាំឆ្នាំ (mutual assessment) រវាងអ្នកដឹកនាំនៅតាមអង្គភាពនីមួយៗ និងមន្ត្រីគ្រប់កម្រិត | ✓ | ✓ | ✓ |
| ៦២ | ៥ | រៀបចំបង្កើតយន្តការផ្ទៃក្នុង សម្រាប់ការផ្តល់មតិស្ថាបនា ដោយធានាការសម្ងាត់ | ✓ | ✓ | ✓ |
| ៦៣ | ៦ | ជំរុញសកម្មភាពនៃកិច្ចសហការផ្ទៃក្នុង ដូចជាសកម្មភាពកីឡា ជាដើម | ✓ | ✓ | ✓ |
| **៤.៣. ការរៀបចំយន្តការលើកទឹកចិត្តសមស្រប** | | | | | |
| ៦៤ | ១ | រៀបចំយន្តការលើកទឹកចិត្ត ដោយផ្អែកលើសូចនាករសមិទ្ធកម្ម កិច្ចខិតខំប្រឹងប្រែង និងស្នាដៃ | ✓ | | |
| ៦៥ | ២ | ដាក់ចេញនូវយន្តការដាក់លាក់ ក្នុងការទទួលស្គាល់ស្នាដៃ តាមរយៈពានរង្វាន់ មេដាយ បណ្ណសរសើរ លិខិតថ្លែងអំណរគុណ ជាដើម | ✓ | ✓ | ✓ |
| ៦៦ | ៣ | ចូលរួមសិក្សាលទ្ធភាពក្នុងការដំឡើងប្រាក់បំណាច់មុខងារសម្រាប់មន្ត្រីស្ថិតិទូទៅ | | ✓ | |
| **គោលដៅយុទ្ធសាស្ត្រទី៥៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល** | | | | | |
| **៥.១. ការអភិវឌ្ឍប្រព័ន្ធឌីជីថលសម្រាប់ការគ្រប់គ្រងទិន្នន័យ** | | | | | |
| ៦៧ | ១ | ដាក់ឱ្យអនុវត្តផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលវិទ្យាស្ថានជាតិស្ថិតិ | ✓ | | |

| | | | | | |
|---|---|---|---|---|---|
| ៦៨ | ២ | អភិវឌ្ឍឃ្លាំងផ្ទុកទិន្នន័យកណ្តាល (date lake) និងវិបផតថលទិន្នន័យជាតិ (National Data Portal - NDP) ជាចំណុចចូលប្រើប្រាស់ទិន្នន័យផ្លូវការតែមួយគត់ | | ✓ | ✓ |
| ៦៩ | ៣ | ធ្វើស្តង់ដានីយកម្មទម្រង់ទិន្នន័យ (Data Format) ដោយរៀបចំនិយាម ឬគោលការណ៍ណែនាំ ដើម្បីធានាបាននូវសង្គតិភាពរវាងសំណុំទិន្នន័យ | | ✓ | ✓ |
| ៧០ | ៤ | ដាក់បញ្ចូលវិធីសាស្ត្រក្នុងការប្រមូលទិន្នន័យថ្មីៗ តាមរយៈ Mobile Data Collection និង Remote Sensing Technologies ជាដើម | | ✓ | ✓ |
| ៧១ | ៥ | ជំរុញអន្តរប្រតិបត្តិការ (Interoperability) ដើម្បីធានាបាននូវភាពបន្សុីគ្នារវាងប្រព័ន្ធផ្ទុកទិន្នន័យរបស់វិទ្យាស្ថានជាតិស្ថិតិជាមួយនឹងប្រព័ន្ធរបស់ក្រសួង-ស្ថាប័ន | | ✓ | ✓ |
| ៧២ | ៦ | រៀបចំផែនការហិរញ្ញប្បទាន សម្រាប់ការអភិវឌ្ឍ និងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធឌីជីថល ដើម្បីធានាថាថ្នាលទិន្នន័យត្រូវបានថែទាំ និងដំណើរការប្រកបដោយនិរន្តរភាព | ✓ | ✓ | ✓ |
| **៥.២. ការធ្វើឌីជីថលូបនីយកម្មរំហូរការងារ** | | | | | |
| ៧៣ | ១ | ដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធឌីជីថល | ✓ | ✓ | |
| ៧៤ | ២ | ជំរុញការធ្វើឌីជីថលូបនីយកម្មនៃរំហូរការងារ និងឯកសាររដ្ឋបាលសំខាន់ៗ | ✓ | ✓ | ✓ |
| ៧៥ | ៣ | ដាក់ឱ្យប្រើប្រាស់ឧបករណ៍ឌីជីថលសាមញ្ញៗ និងកន្លែងផ្ទុកឯកសាររួមឌីជីថល ដើម្បីគាំទ្រដល់កិច្ចសហការ | ✓ | ✓ | ✓ |
| **៥.៣. ការធានាសន្តិសុខទិន្នន័យ** | | | | | |
| ៧៦ | ១ | កំណត់យុទ្ធសាស្ត្រសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិតផ្លូវការ (Cybersecurity Strategy) ដោយគ្របដណ្តប់លើការអ៊ិនគ្រីបទិន្នន័យ និងការការពារហេដ្ឋារចនាសម្ព័ន្ធ | | ✓ | ✓ |
| ៧៧ | ២ | វិនិយោគលើប្រព័ន្ធតភ្ជាប់ដែលមានសមត្ថភាព និងប្រសិទ្ធភាពខ្ពស់ ប្រព័ន្ធផ្ទុកទិន្នន័យក្លោដប្រកបដោយសុវត្ថិភាព និងប្រព័ន្ធបម្រុងស្តុកទុកទិន្នន័យ (Data Backup/DR Systems) | | ✓ | ✓ |
| ៧៨ | ៣ | សិក្សាលើការកំណត់ពីភារកិច្ច និងដែនសមត្ថកិច្ចរបស់វិទ្យាស្ថានជាតិស្ថិតិ លើការធ្វើអភិបាលកិច្ចទិន្នន័យ (Data Stewardship) ក្នុងក្របខ័ណ្ឌនៃប្រព័ន្ធស្ថិតិជាតិ | | ✓ | ✓ |
| ៧៩ | ៤ | រៀបចំ និងដាក់ឱ្យប្រើប្រាស់គោលនយោបាយស្តីពីសិទ្ធិឯកជន និងការការពារទិន្នន័យ (Data Privacy and Protection Policy) | | ✓ | ✓ |